# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ សួន នឿន ភេទស្រី អាយុ៥៨ឆ្នាំ

**មុខងារជំនាន់ខ្មែរក្រហមៈ គ្រូបង្រៀនកុមារ**

**ស្រុកកំណើតនៅភូមិចំរេះ ឃុំគោកចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង**

**រស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ម៉ម សុវណ្ណ**

**០១:២៤:៤៦**

**៣៣ទំព័រ**

សុវណ្ណៈ មីងជំរាបសួរមីង ហើយខ្ញុំសុំណែនាំខ្លួនខ្ញុំម្តងទៀត ខ្ញុំឈ្មោះសុវណ្ណ ហើយគាត់ខាងនេះឈ្មោះបងបូលី ជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃនេះខាងខ្ញុំចុះមកធ្វើការនៅស្រុកត្រពាំងប្រាសាទនេះដើម្បីប្រមែលប្រមូល និងចងក្រងឯកសារដើម្បីសរសេរជាសៀវភៅស្រុកអន្លង់វែង ។ ជំរាបមីងឈ្មោះអីដែរ?

នឿនៈ សួន នឿន ។

សុវណ្ណៈ សួន?

នឿនៈ ចាំ! សួន ទេ ជីតាសួន ។

សុវណ្ណៈ មីងសព្វថ្ងៃអាយុប៉ុន្មាន?

នឿនៈ ខ្ញុំ៥៨ហើយ ។

សុវណ្ណៈ មីងប្រកបមុខរបរធ្វើអីគេ?

នឿនៈ ខ្ញុំប្រកបមុខរបរកន្លងមក ឬឥឡូវ?

សុវណ្ណៈ បច្ចុប្បន្ន?

នឿនៈ បច្ចុប្បន្នខ្ញុំធ្វើស្រែ ។

សុវណ្ណៈ ក្រៅពីធ្វើអីទៀត?

នឿនៈ ក្រៅពីធ្វើស្រែអត់មានធ្វើអី មានតែដុតធ្យូងលក់តិចតួចហើយរបរដែលរកស៊ីចិញ្ចឹមជ្រូកសំរាប់ដោះស្រាយជីវភាពដែលកូនចៅ ទិញសំលៀកបំពាក់ឲ្យកូនចៅស្លៀកពាក់ហូបចុក ។

សុវណ្ណៈ មីងភូមិនេះគេហៅភូមិអីគេ?

នឿនៈ ភូមិទួលចារ ។

សុវណ្ណៈ ឃុំ?

នឿនៈ ឃុំទំនប់ដាច់ ។

សុវណ្ណៈ	ស្រុក?
នឿនៈ	ស្រុកអន្លង់វែង ។
សុវណ្ណៈ	ស្រុកត្រពាំងប្រាសាទ?
នឿនៈ	ហ៎! ស្រុកត្រពាំងប្រាសាទ ។
សុវណ្ណៈ	ខេត្តឧត្តរមានជ័យ?
នឿនៈ	ចា៎! ខេត្តឧត្តរមានជ័យ ។
សុវណ្ណៈ	មីងមានស្រុកកំណើតនៅណា?
នឿនៈ	ខ្ញុំមានស្រុកកំណើតនៅភូមិចំរេះ ឃុំគោកចក ។
សុវណ្ណៈ	ឃុំ?
នឿនៈ	ឃុំគោកចក ។
សុវណ្ណៈ	គោកចក?
នឿនៈ	ចា៎! គោកចក ។
សុវណ្ណៈ	នៅស្រុកណាមីង?
នឿនៈ	ស្រុកកំពង់ត្របែក ។
សុវណ្ណៈ	ស្រុកកំពង់ត្របែក ខេត្តព្រៃវែង?
នឿនៈ	ចា៎! ខេត្តព្រៃវែង ។
សុវណ្ណៈ	មីងមានកូនប៉ុន្មាន?
នឿនៈ	ខ្ញុំកូន៣ ។
សុវណ្ណៈ	ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?
នឿនៈ	ប្រុស២ ស្រី១ ។
សុវណ្ណៈ	សព្វថ្ងៃកូនមានគ្រួសារអស់ហើយមីង?
នឿនៈ	ចា៎! មានអស់ហើយ នៅតែ២នាក់យាយ ហើយនិងតា ។
សុវណ្ណៈ	ចុះកូនមីងនៅរៀនទេ?
នឿនៈ	អស់ហើយ ដាច់អាណត្តិអស់ហើយ ។
សុវណ្ណៈ	មីងមានគ្រួសារឈ្មោះអីគេ?
នឿនៈ	ឈ្មោះ នួន យុង ។
សុវណ្ណៈ	គាត់ធ្វើអីដែរ?
នឿនៈ	គាត់ពីមុនគាត់ធ្វើទាហាន ឥឡូវគាត់កាត់នេះអាត្រែតហើយ ។

សុវណ្ណៈ ទាហានកាលនៅតស៊ូ ទាហានកងពលណាដែរ?

នឿនៈ ទាហានកងពលប៉ុន្មានទេ ។

សុវណ្ណៈ កាលហ្នឹងនៅមួយពាន់ប៉ុន្មាន កាលនៅលើភ្នំ?

នឿនៈ មិនដឹងប៉ុន្មានទេលោកគ្រូខ្ញុំភ្លេចអស់ អត់ច្បាស់ត្រង់ហ្នឹង បើតាបានច្បាស់ តាគាត់ច្បាស់លាស់ ។

សុវណ្ណៈ មីងមានបងប្អូនប៉ុន្មាននាក់?

នឿនៈ ខ្ញុំបងប្អូនបង្កើត៨នាក់ ។

សុវណ្ណៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មានមីង?

នឿនៈ ស្រី៤ ប្រុស៣ ។

សុវណ្ណៈ ៨នាក់ទាំងមីង?

នឿនៈ អីចឹងហើយ៨នាក់ ។

សុវណ្ណៈ ៨ហ្នឹងទាំងមីងតែម្ដង?

នឿនៈ ចាំ!

សុវណ្ណៈ បានន័យថាស្រី៤ ប្រុស៤?

នឿនៈ ចាំ! ស្រី៤ ប្រុស៤ ។

សុវណ្ណៈ មីងកូនទីប៉ុន្មាន?

នឿនៈ ខ្ញុំកូនទី២ ។

សុវណ្ណៈ មីងកាលហ្នឹងមីងនៅក្មេងមីងឈប់រៀនថ្នាក់ទីប៉ុន្មានដែរ?

នឿនៈ ខ្ញុំអត់បានទេ ខ្ញុំមករៀនកាលជំនាន់ប៉ុលពត របប៣ឆ្នាំនេះ ខ្ញុំរៀនដល់ថ្នាក់ទី៤ដល់នេះខ្ញុំឈប់ ខ្ញុំចូលធ្វើគ្រូបង្រៀន ។

សុវណ្ណៈ កាលហ្នឹងមីងរៀនដល់ថ្នាក់ទី៤ រៀនអីគេខ្លះ?

នឿនៈ រៀនថ្នាក់ទី៤ហ្នឹង រៀនតាមអក្សរសាស្រ្តដូចយើងឥឡូវហ្នឹងអីចឹង ។

សុវណ្ណៈ រៀនបន្ទាប់ពី៧៩?

នឿនៈ ខ្ញុំរៀនសម័យហ្នឹងពីដើម៧២ ខ្ញុំរៀនខាងស្អី រៀនជាមួយចាស់ៗអក្ខរកម្ម ដល់ក្រោយមកខ្ញុំចូលសាលាជាមួយក្មេងៗហ្នឹងបាន២ឆ្នាំក៏ឈប់ ឈប់ទៅចុះឈ្មោះធ្វើគ្រូបង្រៀនរហូតទៅតែខ្ញុំរៀនថ្នាក់ទី៤ ។

សុវណ្ណៈ កាលពេលរដ្ឋប្រហារហើយ លន់ នល់ គេទម្លាក់សម្ដេចសីហនុនោះ?

នឿន: ខ្ញុំរត់ពីហ្នឹងមកនៅស្រុកគេរហូតពីរនាក់ប្ដីប្រពន្ធក៏នៅ ចូលពីស្រុកខ្មែរមកនៅក្នុងព្រៃ តាម តាម៉ុក រហូត ។

សុវណ្ណៈ មីងចូលបដិវត្តន៍ឆ្នាំណា?

នឿន: ខ្ញុំធ្វើបដិវត្តន៍តាំងពីឆ្នាំ៧២នោះ ។

សុវណ្ណៈ ចូលបដិវត្តន៍កាលហ្នឹងចូលទៅខាងណា?

នឿន: ខ្ញុំចូលមកខាងខ្មែរក្រហម ។

សុវណ្ណៈ ប៉ុន្តែយើងនៅព្រៃវែងដដែល ឬយើងនៅខេត្តផ្សេង?

នឿន: អត់ទេ នៅក្នុងព្រៃវែង តែខ្ញុំទើបតែចុះពីព្រៃវែងមក៧៩ហ្នឹងខ្ញុំមកនៅនេះម្ដង ។

សុវណ្ណៈ ខ្ញុំចង់ដឹងចេះ មីងចូលបដិវត្តន៍នៅក្នុងព្រៃ ឬក៏?

នឿន: នៅក្នុងព្រៃ ។

សុវណ្ណៈ តែអត់ដឹងថានៅស្រុកណាទេ?

នឿន: ចា៎! អត់នៅស្រុកកំណើតទេ ចេញមកនេះបណ្ដោយ ។

សុវណ្ណៈ ចេញមកនេះ មកខាងណាកាលចូលបដិវត្តន៍?

នឿន: មកចំការគរ ព្រៃមាន់ ។

សុវណ្ណៈ មុំណា?

នឿន: ភ្នំឆត្រ ចំការគរ ព្រៃមាន់ នៅឯដីថៃនោះ មកពីចំការគរ ព្រៃមាន់ហើយខ្ញុំមកនៅភ្នំក្រេង៉ុក

សុវណ្ណៈ ហ្នឹងយើងរត់៧៩?

នឿន: ចា៎! រត់មកពី៧៩ ។

សុវណ្ណៈ កុំអាលហ្នឹងទៅហួសរត់ឆ្ងាយ ខ្ញុំចង់ដឹងថា៧២មីងចូលព្រៃហ្នឹង?

នឿន: អ៎! ៧២ខ្ញុំនៅក្នុងស្រុកទេ ។

សុវណ្ណៈ នៅក្នុងស្រុកអត់ទៅណាទេ?

នឿន: អត់ទៅណាទេ ដល់ពេលយើងមកប៉ែត ។

សុវណ្ណៈ មីងកុំអាលដល់ប៉ែត ខ្ញុំចង់ថាពេលយើងចូលព្រៃគេឲ្យធ្វើអីខ្លះ?

នឿន: មកចូលព្រៃខ្ញុំអត់មានធ្វើអីទេលោកគ្រូ រករបររកស៊ីលក់ដូរធម្មតា ជាបន្លែ ។

សុវណ្ណៈ ចូលព្រៃធ្វើបដិវត្តន៍គេឲ្យរកស៊ីលក់ដូរដែរ?

នឿន: ទេខ្ញុំនៅក្នុងជំរំ តែប្ដីគាត់ធ្វើទាហាន ។

សុវណ្ណៈ មីងកាលហ្នឹងការឆ្នាំណា?

នឿន: ខ្ញុំការ៧៩ ខ្ញុំមកក្នុងចំការគហ្នឹង៧៩ទេ ។

សុវណ្ណៈ ខ្ញុំចង់ថាចូលបដិវត្តន៍៧២ហ្នឹងមីងអត់ទាន់មានគ្រួសារទេ?
នឿនៈ ខ្ញុំនៅលីវ ។
សុវណ្ណៈ នៅលីវចូលជាមួយគេ គេឲ្យធ្វើអីទេកាលនៅលីវក្នុងព្រៃ?
នឿនៈ ខ្ញុំធ្វើអនុប្រធាននារី ។
សុវណ្ណៈ កិច្ចការធ្វើអីខ្លះមីងអនុប្រធាននារី?
នឿនៈ ធ្វើការយើងនៅក្នុងភូមិក្តាប់កំលាំងចេញចូលដើរទៅរកនេះ រកនោះ ដើរទៅណាមកណា ឆ្ងាយជិតអីហ្នឹង ។
សុវណ្ណៈ យើងនៅខាងទ័ព ឬនៅខាង?
នឿនៈ ខាងភូមិ នៅក្នុងភូមិ ។
សុវណ្ណៈ ចុះយើងមានហាត់រៀនទ័ពទេ ហាត់យោធា?
នឿនៈ អត់ទាន់ហាត់ទេកាលហ្នឹង ក្រោយមកខ្ញុំឈប់ធ្វើខាងហ្នឹង គេរើសខ្ញុំឲ្យធ្វើខាងអនុភូមិ ធ្វើប្រធានភូមិ ក្តាប់ខាងអនុភូមិ ។
សុវណ្ណៈ ចុះពេល៧៥ខ្មែរក្រហមគេគ្រប់គ្រងប្រទេសបាន គេមានឲ្យមីងធ្វើអីគេ?
នឿនៈ ៧៥មកខ្ញុំ ។
សុវណ្ណៈ មានជម្លៀសទៅណា ទៅណី?
នឿនៈ ជម្លៀសទៅភូមិថ្មីង ក្បែរព្រំដែនយើងនោះ ។
សុវណ្ណៈ ភូមិថ្មីងក្បែរព្រំដែនខេត្តណាទៅ?
នឿនៈ ព្រំដែនយួន ។
សុវណ្ណៈ ស្ថិតនៅខេត្តណារបស់ខ្មែរ?
នឿនៈ ខេត្តព្រៃវែងហ្នឹងដែរ ។
សុវណ្ណៈ ខេត្តព្រៃវែងដដែល តែយើងចូលទៅដល់ព្រំដែនយួន?
នឿនៈ ចា៎! ដល់ព្រំដែនយួន ។
សុវណ្ណៈ នៅក្នុងស្រុកណាមីងនៅព្រំដែនយួន ខេត្តព្រៃវែង?
នឿនៈ ព្រំដែនយួនភូមិថ្មីងនៅត្បូង គេហៅភូមិ ។
សុវណ្ណៈ ស្រុក ខ្ញុំចង់ដឹងស្រុកអីគេ?
នឿនៈ ស្រុកកំពង់ត្របែកដូចតែគ្នា ។
សុវណ្ណៈ កំពង់ត្របែកដែរ?
នឿនៈ ចា៎!

សុវណ្ណៈ	តែយើងហួសទៅព្រំដែនយួន?

នឿនៈ	ហួសទៅព្រំដែនយួន ទៅដល់ហ្នឹងគេចាត់តាំងឲ្យខ្ញុំធ្វើគ្រូបង្រៀន។

សុវណ្ណៈ	កាលហ្នឹងបង្រៀនក្មេងៗ ឬក៏?

នឿនៈ	បង្រៀនក្មេងៗ កុមារ។

សុវណ្ណៈ	បង្រៀនថ្នាក់ទីប៉ុន្មានកាលហ្នឹង?

នឿនៈ	ទី១។

សុវណ្ណៈ	គេឲ្យមីងធ្វើគ្រូ?

នឿនៈ	ចា៎!

សុវណ្ណៈ	មូលហេតុអីគេឲ្យធ្វើគ្រូ?

នឿនៈ	ព្រោះក្នុងមួយភូមិខ្ញុំចេះអក្សរជាងគេ ដល់អីចឹងហើយគេឲ្យខ្ញុំធ្វើគ្រូ មុនដំបូងគេឲ្យកងចល័តទេ ដល់ពេលគេខ្វះគ្រូ គេហៅពីកងចល័តមកវិញ។

សុវណ្ណៈ	អីចឹងចូលកងចល័តដំបូង?

នឿនៈ	ចា៎! ខ្ញុំមុនដំបូងកងចល័តទេ។

សុវណ្ណៈ	ចល័តភូមិ ឬចល័តឃុំ?

នឿនៈ	ចល័តភូមិ។

សុវណ្ណៈ	កាលហ្នឹងការងារកងចល័តភូមិធ្វើអីខ្លះ?

នឿនៈ	ទេចល័តភូមិអី ចល័តស្រុក ក្រុមនារីចល័តស្រុក។

សុវណ្ណៈ	ធ្វើអីខ្លះក្រុមកងនារីចល័តស្រុក?

នឿនៈ	ដើរជួយស្រូង ជួយដកតាមភូមិ តាមស្រុក។

សុវណ្ណៈ	ចុះពេលខែប្រាំងធ្វើអីគេ?

នឿនៈ	ខែប្រាំងអត់មានធ្វើអីផង ទំនេរដល់ខ្ញុំបានធ្វើគ្រូ ខែប្រាំងធ្វើដីលេខ១ ដែលដីអាចម៍ក្នុងបង្គន់។

សុវណ្ណៈ	មីងធ្វើកងចល័តបានប៉ុន្មានខែ ឬប៉ុន្មានឆ្នាំ បានគេឲ្យយើងចូលធ្វើគ្រូបង្រៀន?

នឿនៈ	ខ្ញុំចូលមួយឆ្នាំ មួយវស្សាយើង។

សុវណ្ណៈ	ហើយគ្រូបង្រៀនគេមានណែនាំត្រឹមត្រូវ? ដូចជាគេមានវិធីសាស្រ្តដល់មីងហើយទៅបង្រៀនក្មេងៗវិញ មានសៀវភៅអានត្រឹមត្រូវទេ?

នឿនៈ មាន របៀបថាយើងទៅរៀនដល់ស្រុក គេហៅទៅរៀន២-៣ថ្ងៃ បង្រៀនជាផ្នែកអក្សរសាស្ត្រក្ដី ឬផ្នែកបច្ចេកទេសខាងយើងធ្វើការក្ដី ខាងលេខនព្វន្តដែលសិស្សហ្នឹងយើងមានវិជ្ជាបង្រៀនក្មេងពន្យល់ពីស្អីៗ ។

សុវណ្ណៈ ហើយចុះពេលទំនេរពីបង្រៀនក្មេងៗ ធ្វើអីគេ?

នឿនៈ ហ្នឹងខ្ញុំដើរបកវំពាក់ ធ្វើជាបង្គី ធ្វើដីលេខ១ ដីលេខ២ ដីលេខ៣ ធ្វើដីលេខ១ ធ្វើដីលាមកធ្វើដីលេខ២ យើងធ្វើដីស្វិកទន្រ្ទានខេត្ត ដីដែលបាតត្រពាំងភក់ៗ បាតត្រពាំង យើងជីកពីបាតត្រពាំងហ្នឹងដាក់តាមមាត់ត្រពាំងហ្នឹងហាលឲ្យស្ងួត យើងដញ្ជូនយកទៅដាក់ក្នុងឃ្លាំងដែលគេធ្វើជាជង្រុកដាក់អីចឹង យកទៅដាក់ទៅឲ្យវាស្ងួត ដល់ពេលខែវស្សាគេយកដីហ្នឹងយកទៅលាវជាមួយលាមក ទី១ ទី២ហ្នឹងគេយកទៅដាក់ស្រែ ដល់វារលួយអស់យើងយកទៅជ្រលក់ដីសំណាបស្ទូង ។

សុវណ្ណៈ ធ្វើគ្រូបង្រៀនបានប៉ុន្មាន គេមានដូរទៅណាទៀតទេ?

នឿនៈ ខ្ញុំធ្វើគ្រូបង្រៀនបាន៣ឆ្នាំ យួនចូល ។

សុវណ្ណៈ ធ្វើបាន៣ឆ្នាំយួនចូលមក?

នឿនៈ ចា៎! យួនចូលក៏ខ្ញុំរត់ ដល់៧៩ខ្ញុំបានប្ដីខ្ញុំមកតាមប្ដីក៏ធ្វើខ្មែរក្រហមជាប់ ។

សុវណ្ណៈ កាលហ្នឹងយួនចូលមកម៉េចរត់តាមគេ?

នឿនៈ រត់តាមម៉ែ តាមឪ មកដល់ស្រុកស្រែម៉ែឪហ្នឹងរៀបចំគ្រួសារឲ្យទៅ បានជាគ្រួសារក៏បែកពីគាត់ គ្រួសារនាំមកនៅស្រុកគេ ទៅធ្វើទាហាន ចេះតែរហូតមកដល់រាល់ថ្ងៃ ។

សុវណ្ណៈ មុនដំបូងយួនចូលមក មីងរត់ទៅនៅជាមួយឪពុកម្ដាយវិញ អត់ទាន់រត់តាមខ្មែរក្រហមទេត្រូវទេកាលហ្នឹង?

នឿនៈ ចា៎!

សុវណ្ណៈ ហើយទាល់តែមីងរៀបការជាមួយពូ ទើបមីងតាមពូ កាលហ្នឹងធ្វើម៉េចបានស្គាល់ពូ?

នឿនៈ គាត់ធ្វើទាហាន ហើយខ្ញុំនៅគ្រូតាមភូមិ ដល់អីចឹងគាត់មកលេងក្នុងភូមិខ្ញុំគាត់ស្គាល់ ខ្ញុំអត់ស្គាល់គាត់ទេ គាត់ស្គាល់ខ្ញុំ ដល់គាត់ស្គាល់អីចឹងទៅ គាត់តាមមកដណ្ដឹងម៉ែ ដណ្ដឹងឪ អីចឹងទៅ ក៏ម៉ែឪរៀបឲ្យ ។

សុវណ្ណៈ កាលហ្នឹងគាត់ជាទាហានរបស់ខ្មែរក្រហម គាត់ម៉េចចេញចូលកើត?

នឿនៈ ចា៎! ទាហានខ្មែរក្រហម ។

សុវណ្ណៈ តែគាត់នៅតែចេញ-ចូលភូមិរបស់មីងបាន?

នឿនៈ ចា៎! ចេញ-ចូលបាន ។

សុវណ្ណៈ	អីចឹងទាហានវៀតណាមឃើញហើយ?

នឿនៈ	អត់ទេ ខ្ញុំនៅក្នុងតំបន់ខ្មែរក្រហម អត់មាននៅតំបន់នៅក្នុងស្រុកយួនទេ ។

សុវណ្ណៈ	អីចឹងមានន័យថាកាលហ្នឹងខ្មែរក្រហមកៀរទាំងមីង កៀរទាំងឪពុកម្ដាយទៅជាមួយគ្នា?

នឿនៈ	ចា៎!

សុវណ្ណៈ	ពេលគេរត់?

នឿនៈ	កាត់ប្រសាសន៍លោកគ្រូបន្តិច កាលហ្នឹងយើងមិនទាន់ច្របូកច្របល់វៃយួនចូលទេ នៅខ្មែរក្រហមកាន់កាប់ពេញសិទ្ធិតែម្ដង ដល់យើងរត់៧៩នេះបានច្របូកច្របល់គ្នាបានយួនចូលស្រុក បានខ្ញុំចេញពីស្រុកមកនៅស្រុកគេនេះ ។

សុវណ្ណៈ	អីចឹង៧៩មីងការខែណា?

នឿនៈ	៧៩ការខែ២ អា៎! ការខែច្រូតហើយ ខែ១ ។

សុវណ្ណៈ	ការហើយភ្លាមយួនចូលមកឬក៏?

នឿនៈ	ច្រូតហើយស្រុកយើងខែ១ហើយ ។

សុវណ្ណៈ	ខ្ញុំចង់និយាយចេះរបបខ្មែរក្រហមកាលហ្នឹងគេដួលរលំនៅថ្ងៃ៧មករា ឆ្នាំ៧៩ ខ្ញុំចង់និយាយថាមីងការមុនដួលរលំ ឬដួលរលំហើយបានការ?

នឿនៈ	ដួលហើយបានការ ។

សុវណ្ណៈ	អីចឹងពេលដែលទាហានយួនចូលមកហ្នឹងមីងរត់ទៅតាមខាងទ័ពខ្មែរក្រហមទេ ទាំងឪពុកម្ដាយរបស់មីង រត់ទៅជាមួយគ្នា កាលហ្នឹងរត់ទៅខាងណា?

នឿនៈ	រត់ ។

សុវណ្ណៈ	រត់ចូលព្រៃ ឬក៏ទៅណា?

នឿនៈ	រត់តាមភូមិ តាមស្រុក ខ្ញុំរត់មកដល់ខាងលិចអ្នកលឿន ។

សុវណ្ណៈ	នៅក្នុងព្រៃឬក៏?

នឿនៈ	នៅតាមភូមិ ។

សុវណ្ណៈ	អីចឹងនៅបានមួយរយៈ ក៏ស្គាល់គ្នារៀបការជាមួយពូទៅ?

នឿនៈ	ហ្នឹងរត់ហើយលោកគ្រូ ដល់យើងវិលត្រឡប់ទៅផ្ទះ ដូចថាឥឡូវរត់មកដល់ខាងលិចអ្នកលឿនយួនចូលមកដល់ វាស្កាត់មុខយើងវិលទៅភូមិវិញ បានតាហ្នឹងឃើញទៅដណ្ដឹងក៏ម៉ែរៀបចំឲ្យ ហើយខ្ញុំរៀបចំហើយនៅបានកូន១ បានខ្ញុំនាំមកនៅស្រុកគេ តស៊ូរហូត ។

សុវណ្ណៈ	អីចឹងការហ្នឹងអំឡុងពេលរត់ដែលទេ?

នឿនៈ	អត់ទេ ចប់ហើយ យួនចូលពេញស្រុកហើយ ។

សុវណ្ណៈ	មីងតាមពូមកខាងណាកាលហ្នឹង?
នឿនៈ	ខ្ញុំមកពីស្រុកមកនៅចំការគរ ព្រៃមាន់ យើងខាងណាទេ ។
សុវណ្ណៈ	ខាងបន្ទាយមានជ័យ?
នឿនៈ	ចំការគរ ព្រៃមាន់មិនដឹងនៅខាងណាទេ ។
សុវណ្ណៈ	ទៅដល់ខាងណាទៀត?
នឿនៈ	ទៅពីចំការគរ ព្រៃមាន់ដិះឡានហ្នឹងចូលដីថៃ ទៅនៅភ្នំក្រដុក យួនវៃពីចំការគរមកព្រៃមាន់ នាំគ្នារត់ទៅនៅភ្នំក្រដុក ដិះឡានបារាំងមកដឹកយកទៅនៅក្រដុកវិញ ។
សុវណ្ណៈ	កាលហ្នឹងយើងទៅចាំនៅកន្លែងហ្នឹងហើយក្រោយមកបានចូលដីថៃ ហើយបានគេដឹកទៅភ្នំក្រដុក?
នឿនៈ	ចា៎! បើប្រវត្តិតស៊ូខ្ញុំច្រើនកន្លែងណាស់ ចេញពីភ្នំក្រដុកខ្ញុំមកនៅស្រែប្រិយ៍ ។
សុវណ្ណៈ	ឈប់កាលហ្នឹងយើងទៅដល់ភ្នំក្រដុកឆ្នាំណា?
នឿនៈ	ឆ្នាំប៉ុន្មានទេ៨៨កាលហ្នឹង ។
សុវណ្ណៈ	តាមពូចេញពី៧៩ត្រូវទេមីង?
នឿនៈ	តាមតាចេញពី៧៩មក ។
សុវណ្ណៈ	ចេញពី៧៩យើងទៅនៅកន្លែងណាខ្លះ៧៩ហ្នឹង?
នឿនៈ	៧៩ខ្ញុំមកនៅស្រុកគ្រួសារខ្ញុំបាន១ឆ្នាំបានខ្ញុំមកនៅចំការគរ ។
សុវណ្ណៈ	ចេញពីចំការគរទៅណាទៀត?
នឿនៈ	ចេញពីចំការគរទៅនៅរហូតដល់ភ្នំក្រដុក ។
សុវណ្ណៈ	ហើយទៅភ្នំក្រដុកទៅនៅធ្វើអីខ្លះនៅហ្នឹង?
នឿនៈ	នៅភ្នំក្រដុកអត់មានធ្វើអីទេ ដេកហូបអង្ករគេបើក នៅហ្នឹងទៅ ដល់ពេលគេប៉ះបោរត់ពីក្រដុកមកវិញខ្ញុំមកនៅស្រែប្រិយ៍ យួនកៀរដេញតាមរហូតដល់ហ្នឹងដែរ ។
សុវណ្ណៈ	ដល់ពេលពូនៅខាងណាវិញ? កាលហ្នឹងនៅជាប់គ្នាឬនៅបែកគ្នា កាលទៅនៅភ្នំក្រដុក?
នឿនៈ	ខ្ញុំចេញពីក្រដុកមកនៅជុំគ្នាទេ មកដល់ហ្នឹងស្រែប្រិយ៍ក៏ជុំគ្នាដែរ មកដល់៨៥បែកគ្នា គាត់ទៅទាហាន គេដឹកខ្ញុំមកពីស្រែប្រិយ៍ហ្នឹងមកដល់៨៥ហ្នឹងក៏ខ្ញុំនៅតែឯង រកស៊ីចិញ្ចឹមកូន ។
សុវណ្ណៈ	៨៥មីងមកនៅណាវិញ?
នឿនៈ	៨៥មកខាងនេះវិញ ចេញពី៨៥ហ្នឹងហើយបាន ។
សុវណ្ណៈ	មកខាងនេះមកខាងណា?
នឿនៈ	មកខាងហ្នឹងវិញ ។

សុវណ្ណៈ	មកខាងក្នុងដងរែកនេះ?
នឿនៈ	មកខាងក្នុងដងរែកវិញ ។
សុវណ្ណៈ	មកដល់កន្លែងណា? ទៅដល់១០០១, ១០០២, ១០០៣?
នឿនៈ	បែបមកដល់ហ្នឹង១០០៣ហើយ ។
សុវណ្ណៈ	មក១០០៣កន្លែងគេហៅអីគេ?
នឿនៈ	ឯណា?
សុវណ្ណៈ	១០០៣លើភ្នំគេហៅអីគេ? កន្លែងហ្នឹង?
នឿនៈ	កន្លែងហ្នឹងហៅដាំស្វា ។
សុវណ្ណៈ	ចុះទន្លេល្អៅ?
នឿនៈ	ទន្លេល្អៅខ្ញុំអត់បាននៅផង ។
សុវណ្ណៈ	តែទន្លេល្អៅគេហៅតំបន់មួយពាន់ប៉ុន្មាន?
នឿនៈ	ទន្លេល្អៅមិនដឹងតំបន់មួយពាន់ប៉ុន្មានទេ ខ្ញុំអត់ដឹងផង វាបែកគ្នា វាមាន២បក្ស យាយដែលដើរពាក់អាវឆ្នូតមិញយាយហ្នឹងនៅខាងទន្លេល្អៅ ។
សុវណ្ណៈ	ចុះមីងនៅខាងណា?
នឿនៈ	ខ្ញុំនៅខាង៨៥ នៅខាងដែលអណ្តែងមុតនៅកណ្តាលដីថៃ ខ្ញុំនៅអណ្តែងមុតនៅ៣ឆ្នាំ ។
សុវណ្ណៈ	ចុះពេលចេញពីនោះមក? ជិះមក?
នឿនៈ	ជិះឡាន ។
សុវណ្ណៈ	កាលមក១០០៣ជិះឡានមកតាមដីថៃ?
នឿនៈ	ចាំ! គេដឹកមក ។
សុវណ្ណៈ	ឡានហ្នឹងឡានរបស់ខាងថៃអ្នកដឹកមក ឬក៏ខាងខ្មែរក្រហមគេដឹកមក?
នឿនៈ	ខ្មែរក្រហម ។
សុវណ្ណៈ	ខ្មែរក្រហមគេដឹកមក?
នឿនៈ	ចាំមើលគេដឹកកាលហ្នឹងមាន២បក្សដែរ ឡានវាមាន២ គេសួរសំរេចយើងថា មេក្រុគេប្រកាសថាបងប្អូនណាទៅខ្មែរក្រហមជិះឡានខៀវ បងប្អូនណាទៅសម្ពរឆ្នាញ់ជិះឡានស គេមានសម្ពរឆ្នាញ់គេទៅខាងបារាំ តែគេសួរចិត្តយើងដែរ បងប្អូនណាស្ម័គ្រចិត្តទៅសម្ពរឆ្នាញ់ៗ បងប្អូនណាស្ម័គ្រចិត្តទៅម៉ាឡៃជិះឡានខៀវ ខ្ញុំថាស្ម័គ្រចិត្តទៅម៉ាឡៃទៅខ្មែរក្រហម ខ្ញុំអត់ស្ម័គ្រចិត្តទៅខាងបារាំទេ ។
សុវណ្ណៈ	អីចឹងទៅម៉ាឡៃទេ ។

ធឿនៈ ចា៎!

សុវណ្ណៈ កាលហ្នឹងមីងចេញពីណាវិញ?

ធឿនៈ ចេញពី៨៥មកទៅម៉ាឡៃ ។

សុវណ្ណៈ ថ-៨៥មីង?

ធឿនៈ ចា៎!

សុវណ្ណៈ បន្ទាយទាហានហ្នឹង?

ធឿនៈ អត់ទេ នៅក្នុងជំរំ ។

សុវណ្ណៈ ជំរំថ-៨៥?

ធឿនៈ អត់ទេ ជំរំតាម៉ុកវិញ ។

សុវណ្ណៈ ទិញដីថៃហ្នឹង?

ធឿនៈ ចា៎! ទិញនៅដីថៃឲ្យខ្មែរយើងនៅ ។

សុវណ្ណៈ អីចឹងចេញពីថ-៨៥មកម៉ាឡៃ?

ធឿនៈ ចា៎! មកម៉ាឡៃ ។

សុវណ្ណៈ មកម៉ាឡៃកាលហ្នឹងមកនៅតំបន់ខាងណា?

ធឿនៈ នៅតំបន់ណាទេ ។

សុវណ្ណៈ នៅខាងបឹងបេង ឬនៅខាងណា?

ធឿនៈ ចា៎! មកខាងបឹងបេង ។

សុវណ្ណៈ កន្លែងហ្នឹងម៉េចគេដាក់បឹងបេងអីចឹងមីង?

ធឿនៈ ដាក់បឹងបេង ។

សុវណ្ណៈ មូលហេតុអីបានគេដាក់ឈ្មោះភូមិបឹងបេង?

ធឿនៈ កាលហ្នឹងបឹងបេងដាក់ក្រោយទេ កាលខ្ញុំនៅគេដាក់ភូមិដូង ។

សុវណ្ណៈ បឹងបេងដាក់ក្រោយទេ?

ធឿនៈ បឹងបេងដាក់ក្រោយ ដាក់បឹងបេងខ្ញុំចេញហើយ ចេញហើយបានគេដាក់ឈ្មោះបឹងបេង កាលខ្ញុំនៅគេដាក់អូរស្រឡៅ ។

សុវណ្ណៈ អ៎! នៅខាងម្តុំអូរស្រឡៅ?

ធឿនៈ ចា៎! ឃុំអូរស្រឡៅ ភូមិដូងអីចឹង ។

សុវណ្ណៈ ឃុំអូរស្រឡៅ?

ធឿនៈ ចា៎!

សុវណ្ណៈ	តែមុនគេហៅអូរស្រឡៅ ហើយមកម៉ាឡៃមកនៅខាងអូរស្រឡៅទេ?

នឿនៈ	ចា៎!

សុវណ្ណៈ	ហើយមកដល់ហ្នឹងយើងធ្វើអីខ្លះ?

នឿនៈ	ខ្ញុំអត់មានធ្វើអីទេ នៅដេកហូបអង្ករគេបើកធម្មតា ។

សុវណ្ណៈ	អង្ករគេបើករបៀបម៉េច?

នឿនៈ	គេបើកតាមកាកបាទបើកឲ្យ តាមស្បោង ។

សុវណ្ណៈ	មួយខែគេបើកម្តង? មួយអាទិត្យគេបើកម្តង?

នឿនៈ	មួយអាទិត្យគេបើកម្តង ។

សុវណ្ណៈ	ម្តងគេបើកបានប៉ុន្មានគីឡូ?

នឿនៈ	មួយអាទិត្យហ្នឹងបើកមួយស្បោងយើងស អាហ្នឹងប្រហែលជាមិនបាន៥០គីឡូទេ បាន៤០ គីឡូ ។

សុវណ្ណៈ	កាលហ្នឹងមីងមានកូននៅ?

នឿនៈ	ខ្ញុំកូន២ហើយ ។

សុវណ្ណៈ	អីចឹងគេបើកតាមចំនួនគ្រួសារ?

នឿនៈ	ចា៎! បើកតាមមាត់ បើកតាមគ្រួសារ ហើយត្រីខគេបើកតាមគ្រួសារដែរ ។

សុវណ្ណៈ	ក្រៅពីអង្ករគេមានបើកអីផ្សេងទៀតទេ?

នឿនៈ	បើកអង្ករ, ត្រីខ, ប្រហុក, ខ្ទឹម, ស្ករ, សណ្តែកបាយ បើកមួយចប់តាំងពីត្រីប្លាធូរ សំរាប់គ្រឿងហូបចុកយើងដោះស្រាយជីវភាពបើកមួយចប់ ប៊ីចេង, អំបិល, ទឹកត្រី គេបើកមួយចប់ឲ្យ ។

សុវណ្ណៈ	ខាងណាគេបើកឲ្យ?

នឿនៈ	រដ្ឋយើងបើក ខ្មែរក្រហមគេបើក ។

សុវណ្ណៈ	កាលហ្នឹងនៅម៉ាឡៃអ្នកណាគ្រប់គ្រង?

នឿនៈ	នៅម៉ាឡៃតាជឿន ។

សុវណ្ណៈ	មិនមែនអ៊ីអៀង សារីទេ?

នឿនៈ	មេធំខ្ញុំអត់សូវស្គាល់ទេ ស្គាល់តែមេតូចៗ ។

សុវណ្ណៈ	តាជឿន?

នឿនៈ	តាជឿន ខាងឃុំ ។

សុវណ្ណៈ	ខាងគ្រប់គ្រងភូមិ?

នឿនៈ ឃុំ ។

សុវណ្ណៈ តាជឿន គណៈគ្រប់គ្រងឃុំទេ?

នឿនៈ ចាំ!

សុវណ្ណៈ ចុះពេលស្រុក?

នឿនៈ ស្រុកខ្ញុំអត់សូវស្គាល់ផង ។

សុវណ្ណៈ ចុះអ្នកគ្រប់គ្រងធំនៅខាងមាត់ឡៃហ្នឹង?

នឿនៈ ហ្នឹងខ្ញុំអត់សូវស្គាល់តែម្ដង ហើយគេប្រជុំមិនសូវប្រជុំញឹកដូចកាលនេះផង ដូចខ្មែរក្រហម ប្រជុំហៅតែមេៗទៅ មេក្រុម ភូមិ ឃុំ គេហៅទៅ អីចឹងភូមិ ឃុំ ក្រុមយកមកផ្សព្វផ្សាយតាមភូមិ ហៅប្រជាជនទៅប្រជុំតាមភូមិ អីចឹងខ្ញុំអត់សូវស្គាល់មេធំៗ ស្គាល់តែមេទាបៗ តូចៗ ។

សុវណ្ណៈ ចុះយើងមានរកស៊ីអីដោះដូរជាមួយថៃកាលហ្នឹង?

នឿនៈ ខ្ញុំមិនដែលរកស៊ីអីទេ ។

សុវណ្ណៈ ចង់ថាប្រជាជនផ្សេងៗ?

នឿនៈ ខ្ញុំទៅធ្វើការឲ្យថៃ ទៅតែបេះម្ទេសបិគក់ កាច់ពោត ជីកដំឡូង ទៅរកស៊ីឈ្នួលថៃ ។

សុវណ្ណៈ គេឲ្យយើងមួយថ្ងៃប៉ុន្មានកាលហ្នឹងស៊ីឈ្នួលថៃ?

នឿនៈ ពោតមួយបាវវាតែ២៥ បើកាប់ម្ទេសបិគក់គេហៅកញ្ជេហ្នឹង៣ពាន់ ។

សុវណ្ណៈ ៣ពាន់បាត?

នឿនៈ ៣០ បាត ។

សុវណ្ណៈ ហើយមួយថ្ងៃយើងកាប់បានប៉ុន្មានកញ្ជេទៅ?

នឿនៈ ខ្ញុំបើប្រឹងមែនទែនមួយថ្ងៃវាលល្ងាចបាន៥កញ្ជេ ។

សុវណ្ណៈ បាន១៥០ បាតដែរ?

នឿនៈ ចាំ! បើកាច់ពោតខ្ញុំកាច់មិនបាននឹងគេទេ ១ថ្ងៃបានតែ៣បាវ ។

សុវណ្ណៈ ៣បាវយើងបាន៦០ បាតដែរ ។

នឿនៈ ២៥បាត ។

សុវណ្ណៈ យើងបាន៧៥ដែរ មានអីផ្សេងទៀតទេដែលយើងរកស៊ីដោះដូរជាមួយថៃ ក្រៅពីទៅធ្វើការហ្នឹង?

នឿនៈ ខ្ញុំគ្មានរកស៊ីអីទេ ខ្ញុំទៅរកស៊ីតែឈ្នួលថៃតិចតួច កាច់ពោត បើថារកស៊ីអីផ្សេងៗមិនដែលរកទេ ។

សុវណ្ណៈ ចុះមេធំៗរបស់គេឃើញគេរកស៊ីអីខ្លះ?

នឿនៈ ខ្ញុំមិនឃើញរកអីទេមេ ឃើញតែប្រជាជនវែកឥវ៉ាន់លក់តាមភូមិដែរ ប្រជាជនថៃ មេៗគេមិនដឹងគេរកស៊ីអី ។

សុវណ្ណៈ មានរកស៊ីឈើ, រ៉ែ ដោះដូរឥវ៉ាន់ មកដឹកជញ្ជូនពីខ្មែរទៅមានទេ?

នឿនៈ មិនដែលឃើញ បើប្រជាជនវាមានទិញអង្ករយើង មានមកទិញត្រីខ ទិញខ្លាញ់ ទិញសណ្ដែកបាយ ទិញក្លួយ មុង ទិញជាខោអាវទាហាន ទិញជាអង្រឹង ហ្នឹងប្រជាជនវាទិញមកទិញពីយើងយកទៅ តែបើមេគេធំៗមិនមានមកផង អត់មានចូលក្នុងជំរំផង ។

សុវណ្ណៈ កាលហ្នឹងយើងដោះដូរលុយអីគេដែរ?

នឿនៈ ចាយលុយបាតដែរ ។

សុវណ្ណៈ អត់ចាយលុយខ្មែរយើងទេ?

នឿនៈ អត់ទេ ។

សុវណ្ណៈ ម៉េចអ៊ីចឹងមីង?

នឿនៈ កាលហ្នឹងនៅនឹងដីថៃ ចាយលុយបាត អត់ដែលមានឃើញខ្មែរយកទៅដល់ផង ។

សុវណ្ណៈ គ្រប់គ្រាន់ទេកាលហ្នឹងមីងយើងហូបចុក?

នឿនៈ គ្រប់នោះដូចមិនគ្រប់ដែរ កាលណារដ្ឋយកអង្ករមិនទាន់មកដល់យើងខ្វះខាត១-២ថ្ងៃដែរ វាមិនបានគ្រប់រហូតប្រចាំខែ ប្រចាំថៃរហូត ដូចថាសេដ្ឋកិច្ចដោះស្រាយមិនទាន់ មានខ្វះ១-២ថ្ងៃបានមកដល់ ម្ហូបអីក៏ដោយ ឲ្យតែរបស់យើងត្រូវដោះស្រាយជាក្រពះវាមានខ្វះខាតខ្លះ វាមិនគ្រប់គ្រាន់ទាំងអស់ ដូចថាខ្វះខាតជាអំបិល ប្រហុក យើងដើរសុំគ្នាយើងហូបជិតៗហ្នឹងទំរាំតែគេបើកមកដល់ គេបើកឲ្យយើងហូប មានខ្វះខាតដែរ វាមិនថាសព្វបែបទាំងអស់ មួយខែទល់មួយខែគ្រប់គ្រាន់ទាំងអស់ទេ ដូចថាយកមកមិនទាន់ ឡានដឹកមិនទាន់

សុវណ្ណៈ ដល់ពេលខ្វះខាតយើងធ្វើម៉េច?

នឿនៈ ដើរខ្ចីគ្នាហូប ឬសុំគ្នាហូបទៅ ដូចថាយើងអត់ អ្នកនៅទៅសុំគ្នាហូប កាលហ្នឹងមិនមានទិញមិនមានបុលទេ មានតែសុំហើយនិងខ្ចី ។

សុវណ្ណៈ ចេញពីម៉ាឡៃមកនេះ មកភ្នំដងរែកនេះឆ្នាំណា? ចេញពីនោះឆ្នាំណាកាលហ្នឹង?

នឿនៈ មកភ្នំដងរែក៨០ ខ្ញុំមកពីនោះ៨១ ។

សុវណ្ណៈ ៨១ចេញពីម៉ាឡៃមកភ្នំដងរែក?

នឿនៈ ចាំ!

សុវណ្ណៈ មកហ្នឹងមីងមកជាមួយពូប្អូនអត់ទេ?

នឿនៈ ខ្ញុំទៅជាមួយគាត់ គាត់ធ្វើទាហានដែរតែគាត់ដូចថាមកលេង ដល់គេដឹកទៅៗតាមប្រពន្ធ ដល់នោះធ្វើខ្លួនឲ្យប្រពន្ធហើយរួចរាល់បានគាត់ចេញវិញ ។

សុវណ្ណៈ អីចឹង៨១មីនមកដល់ភ្នំដងរែក?

នឿនៈ ចា៎!

សុវណ្ណៈ មកដល់ហ្នឹងនៅខាង១០០៣?

នឿនៈ ចា៎! នៅខាង១០០៣កាលហ្នឹង ។

សុវណ្ណៈ ពីណាគេគ្រប់គ្រងកាលហ្នឹងនៅ១០០៣?

នឿនៈ ១០០៣មិនដឹង តាខៀវដឹងកាលហ្នឹង តាអៀង សារី ដែលគេសម្លាប់ចោល ។

សុវណ្ណៈ មិនមែនគេសម្លាប់ចោលទេ គាត់ឈឺស្លាប់ ។

នឿនៈ ទេតាមួយដែលគេសម្លាប់មួយពូជ ។

សុវណ្ណៈ តាសុន សេន?

នឿនៈ ចា៎! នៅជាមួយតាហ្នឹង ។

សុវណ្ណៈ អីចឹងមកនៅ១០០៣ជាមួយអ៊ំសុន សេន?

នឿនៈ ចា៎! នៅជាមួយតា ។

សុវណ្ណៈ កាលហ្នឹងសុន សេន គាត់គ្រប់គ្រងកងពលណាខ្លះ? ដឹងទេមីង?

នឿនៈ ខ្ញុំមិនសូវដឹងទេ បើតាបានច្បាស់ណាស់ ។

សុវណ្ណៈ ដល់ពេលមកពូនៅទ័ពនៅឡើយមិនទាន់ចេញទេ?

នឿនៈ គាត់នៅ ។

សុវណ្ណៈ ពេលចេញពីម៉ាឡៃពីណាគេទៅយកមក? មកនៅ១០០៣ អ្នកណាដឹកមក?

នឿនៈ ចេញពីម៉ាឡៃអង្គការគេដឹកទៅ គេជម្លៀសយើងទៅ ។

សុវណ្ណៈ គេប្រាប់ថាម៉េច?

នឿនៈ គេឲ្យយើងទៅនៅហ្នឹងទៅ នេះវាមិនធានាសុវត្ថិភាពគេថាដឹងយួនប្រុងចូលមក ប្រុងវ៉ៃ មិនធានាសុវត្ថិភាពក៏ដឹកទៅ ។

សុវណ្ណៈ មកនៅ១០០៣មីងធ្វើអីខ្លះ? ការងារនៅ១០០៣?

នឿនៈ ខ្ញុំអត់ធ្វើអីផង ខ្ញុំនៅមើលតែកូន កាលហ្នឹងខ្ញុំមានកូន២ហើយ ។

សុវណ្ណៈ ចុះអ្នកនៅលីវគេធ្វើអីគេខាងស្រីៗ មីងៗ?

នឿនៈ ខាងដឹកជញ្ជូនជាគ្រាប់ អង្ករ អំបិល ប៊ីចេង ប្រហុក ស្ករ បន្លែ ដឹកយកទៅឲ្យទ័ពនៅមុខ នៅខ្សែត្រៀម ។

សុវណ្ណៈ	មីងមានចាក់ចំរូងខ្លះទេកាលហ្នឹង?

នឿនៈ	ខ្ញុំនៅក្រោយមីងៗទាំងអស់គេឲ្យបិទចំរូង បិទបានយើងរាយការណ៍ ក្នុងមួយគ្រួសារគេកំណត់ឲ្យយើងក្នុងមួយថ្ងៃ៥០០ក្នុងមួយគ្រួសារ អ្នកមានកូនខ្ចីគេកំណត់ឲ្យ២៥០-៣០០ ហើយដូចអ្នកអត់កូនខ្ចីគេកំណត់ឲ្យ៥០០-៨០០-១០០០ចំរូង អ្នកធ្វើបិទហ្នឹងខំបិទ ដូចខ្ញុំអត់កូន អត់ចៅនឹងគេឡើងទៅកាប់ឫស្សីលើភ្នំ យកមកចែកឲ្យអ្នកពោះធំ ចែកឲ្យអ្នកកូនខ្ចី ដូចថាអ្នកពោះធំគ្នាឡើងទៅមិនរួចឲ្យមួយដើម អ្នកកូនខ្ចីគ្នាធ្វើអីមិនបានក៏ទៅមិនរួចដាប់កូនចៅឲ្យមួយដើម ខ្លួនឯងទុកមួយដើម ដល់ពេលអស់មិនគ្រប់យើងឡើងទៅវេចបាយកញ្ចប់ឡើងទៅកាប់ទៀត បាន៣ដើមមកលីមកដល់ចែកអ្នកកូនខ្ចីមួយដើម ចែកពោះធំមួយដើម នៅខ្លួនឯងមួយដើម ។

សុវណ្ណៈ	ក្រៅពីការងារបិទចំរូងយើងធ្វើទៀតមីងកាលហ្នឹងនៅ១០០៣?

នឿនៈ	ក្រៅពីការងារបិទចំរូងមកមានតែកាប់ចំការដើម្បីដាំស្រូវឲ្យកូនហូបតិចតួច ដោះស្រាយជីវភាព ។

សុវណ្ណៈ	តែរបបគេនៅបើកឲ្យយើងហូបធម្មតា?

នឿនៈ	របបគេឈប់បើកហើយអង្ករ គេបើកខាងប្រហុក ប៊ីចេង អំបិល ស្ករ ។

សុវណ្ណៈ	អង្ករឈប់បើកហើយកាលហ្នឹង?

នឿនៈ	គេឈប់បើកធ្វើបានខ្លួនឯងគេឈប់បើកឲ្យហើយ ។

សុវណ្ណៈ	ពេលណាគេឈប់បើកឲ្យយើង?

នឿនៈ	ពេលយើងធ្វើបានធានាសុវត្ថិភាពយួនលែងមកដល់ ។

សុវណ្ណៈ	ឆ្នាំណាកាលហ្នឹង?

នឿនៈ	ឆ្នាំប៉ែតប៉ុន្មានទេ ៩១ ខ្ញុំភ្លេចទៅមិនបានយកចិត្តទុកដាក់ ។

សុវណ្ណៈ	យើងចុះពីលើភ្នំមកនៅក្រោម ដំបូងយើងចុះមកឆ្នាំណា?

នឿនៈ	ខ្ញុំ៩២ហើយខ្ញុំចុះមកនៅហ្នឹងតែម្តង ។

សុវណ្ណៈ	អីចឹង៩២មីងចុះមកនៅហ្នឹងតែម្តង?

នឿនៈ	ចាំ!

សុវណ្ណៈ	អត់មានដូរទៅណាទេ?

នឿនៈ	អត់មានទៅណាទេ ដល់ពេលមកនៅនេះបាន៣ឆ្នាំយួនគេវ៉ៃមក ។

សុវណ្ណៈ	វ៉ៃមកតាមត្រាំបោង?

នឿនៈ ចា៎! វ៉ៃតាមគ្រាំបោង ព្រោះខ្ញុំរត់ទៅនៅតាមដើងភ្នំៗ ហើយអត់បានចូលដីថៃទេ ទៅនៅតែដើងភ្នំ ទទួលគ្រួសារខ្ញុំផ្តាច់ខ្លួនអីក្នុងនាំទាហាន៣០០ យករថក្រោះមក៣គ្រឿងមកវ៉ៃបានបែកតាម៉ុក ។

សុវណ្ណៈ មីងកុំអាលគិច ខ្ញុំចង់ថា៩២មីងចុះមកនៅក្រោមនេះ?

នឿនៈ ចា៎!

សុវណ្ណៈ ចុះមកនៅខាងភូមិទួលចារត្រូវទេ?

នឿនៈ ចា៎! នៅភូមិទួលចារហ្នឹងនៅបាន៣ឆ្នាំ ។

សុវណ្ណៈ ៣ឆ្នាំយើងរត់ទៅណាទៀត?

នឿនៈ រត់ទៅនៅដើងភ្នំអស់នេះ នៅជិតៗហ្នឹងដែរ ។

សុវណ្ណៈ រត់ទៅខាងណា ទៅខាងអូរស្មាយ?

នឿនៈ ចា៎! ទៅខាងអូរស្មាយថ្មីយើងហ្នឹង ។

សុវណ្ណៈ ឈ្មោះអូរស្មាយ ឬក៏អូរស្មាយថ្មី?

នឿនៈ អូរស្មាយនេះអូរស្មាយចាស់ នេះអូរស្មាយថ្មី តែវាអូរតែមួយ ។

សុវណ្ណៈ អីចឹងអូរស្មាយមាន២?

នឿនៈ មានពីរ ។

សុវណ្ណៈ មានអូរស្មាយថ្មី?

នឿនៈ អូរស្មាយចាស់ ។

សុវណ្ណៈ អីចឹងមីងកាលហ្នឹងរត់ទៅនៅអូរស្មាយថ្មី?

នឿនៈ ចា៎!

សុវណ្ណៈ រត់ទៅនៅហ្នឹងបានប៉ុន្មាន?

នឿនៈ រត់ទៅនៅហ្នឹងមិនទៀងទេ ទៅនៅជិតៗហ្នឹង ទៅនៅ២ឆ្នាំបានវិលមកនៅនេះវិញ ។

សុវណ្ណៈ ចុះមីងរត់ទៅនោះថាម៉េចវ៉ៃតាម៉ុក?

នឿនៈ រត់ទៅនៅនោះ នៅអូរស្មាយថ្មី តាម៉ុក ក្បត់ ។

សុវណ្ណៈ ម៉េចតាម៉ុក ក្បត់?

នឿនៈ តាម៉ុក ក្បត់ដូចថា ក្បត់ពីតាប៉ុល ពត, តាសារឿន, តាសាន ក្បត់តាប៉ុន្មាននាក់ហ្នឹង ហើយមិនចូលដៃចូលជើងខាងពួកបារាំ៉ង ហើយកាលហ្នឹងពួកតាម៉ុក ធ្វើល្បិចយកយន្តហោះមេៗទាហានបារាំ៉ងយកដុតចោលមួយ ពួកហ្នឹងក៏ចាញ់នយោបាយតាម៉ុក ដល់ក្រោយមក

តាម៉ុក គាត់លាងខ្លួនស្អាត ទទួលរដ្ឋាភិបាលហ្នឹងក៏រួបរួមគ្នា ចូលគ្នា លែងមានតាម៉ុក មិនតាម៉ុក ចូលនៅភ្នំពេញ គេយកទៅឃុំឃាំងគុកទួលស្លែង ។

សុវណ្ណៈ អីចឹងទៅនៅអូរស្វាយ ខាងពូនេះផ្ដាច់ខ្លួនចូលជាមួយរដ្ឋាភិបាល កាលហ្នឹងផ្ដាច់ខ្លួនចូលជាមួយគេឆ្នាំណា? ជាមួយរដ្ឋាភិបាល?

នឿនៈ មិនដឹងឆ្នាំណាលោកគ្រូ គាត់ទៅមិនទាន់បានមួយអាទិត្យផង ទៅបានតែ៣ថ្ងៃ ។

សុវណ្ណៈ ទៅអូរស្វាយហ្នឹង?

នឿនៈ អត់ទេ គាត់ទៅផ្ដាច់ខ្លួនទៅបានតែ៣ថ្ងៃ ។

សុវណ្ណៈ អីចឹងមីងចាំនៅអូរស្វាយ?

នឿនៈ ខ្ញុំនៅអូរស្វាយធ្វើផ្ទះមួយប៉ុណ្ណឹងដែរ ។

សុវណ្ណៈ មីងចាំនៅអូរស្វាយ ហើយពូទៅផ្ដាច់ខ្លួនហើយចូលជាមួយរដ្ឋាភិបាលមកវិញជាមួយតាម៉ុកនេះមក?

នឿនៈ មកវិញជាមួយតាម៉ុក ក៏បានឯករាជ្យទល់ឥឡូវទៅ ។

សុវណ្ណៈ កាលហ្នឹងគេថាតាម៉ុក ចាប់ពូទៅម៉េចទៅ? ហើយចាប់មីងទៅឃុំដែលម៉េចទៅ?

នឿនៈ ឪវាទៅផ្ដាច់ខ្លួនគេចាប់ខ្ញុំទៅឃុំ ហើយឪវាមុនដំបូងគេផ្សាយទ្រុងដែកហ្នឹងប្រុងចាប់គាត់យកទៅដាក់ទ្រុង ហើយមានអ្នកអាណិតគេមកប្រាប់ គេមកប្រាប់ថា “បងឯងមានលឺឡានរត់ពួនទៅ គេផ្សារទ្រុងហើយគេចាំគាត់ហើយ ចាប់ហ្នឹង៣នាក់ មានតាពិននេះមួយ ហើយចាប់ប្អូនតាសារឿន នេះមួយ ហើយគ្រួសារខ្ញុំ” ដល់គាត់ដឹងខ្លួនអីចឹង តានេះនៅត្រពាំងប្រាសាទគាត់ទៅផ្ដាច់ខ្លួនមុន៣គ្រួសារនោះ ដល់អីចឹងហើយគាត់ទាក់ទងតាមគេអូពីនោះមកដល់ទទួលផ្សារដែកប្រុងចាប់៣នាក់ទៀត គាត់ហ្នឹងក៏ប្រមូលទ័ព ។ ហើយខ្ញុំគ្មានដឹងអីបន្តិចសោះ គាត់ទៅគាត់គ្មានប្រាប់ គ្រាន់តែសរសេរសំបុត្រអក្សរមួយតួផ្ញើរមកគេ “ឲ្យខ្ញុំលាក់កាំភ្លើង” កាំភ្លើង គ្រាប់នៅលើផ្ទះប៉ុន្មានឲ្យខ្ញុំលាក់ទាំងអស់ ហើយមិនបាច់និយាយទេ គាត់សរសេរសំបុត្រតែមួយតួទេ យកមកឲ្យខ្ញុំ សំបុត្រថាមួយចង្អរមចុះ គាត់សរសេរមក ឲ្យខ្ញុំយកកាំភ្លើងលាក់ ខ្ញុំគ្រាន់តែមើលសំបុត្រហ្នឹងហើយខ្ញុំឆ្ងល់ខ្លួនឯង ខ្ញុំថាមានរឿងហេតុអីបានឲ្យខ្ញុំលាក់កាំភ្លើង លាក់គ្រាប់ ក្នុងផ្ទះហ្នឹង ខ្ញុំចេះតែឆ្ងល់ខ្លួនឯង តែខ្ញុំធ្វើតាមគាត់ដែរ ។ ខ្ញុំលាក់កាំភ្លើង លាក់គ្រាប់បែក លាក់គ្រាប់អាការទាំងកេះៗខ្ញុំយកលាក់ ហើយបញ្ចេះឃើតសំរាប់ខ្សែឃើតមីនក៏ខ្ញុំលាក់អស់ លាក់ហើយតែល្ងាចហ្នឹងស្អែកឡើងតាម៉ុក គេមកចាប់ខ្ញុំយកទៅឃុំឃាំងនៅអន្លង់វែង ស្អានហ្នឹងគេយកឡានមកដឹកខ្ញុំ យកទៅ ។

សុវណ្ណៈ គេមកដល់គេថាម៉េច?

នឿនៈ មកគេថាឲ្យយើងរៀបចំអង្ករ រៀបចំចានឆ្នាំងឲ្យយើងទៅនៅហ្នឹង ហើយខ្ញុំហ្នឹងក៏រៀបទៅ គេយកឡានធំមកដឹក ហើយគេប្រាប់ថាឲ្យយកអង្ករយកទៅស៊ីកំណត់រូបកុំឲ្យខ្វះ តែមិនដឹងរូបហ្នឹងប៉ុន្មានគេ គេឲ្យថាម៉ារូប ក៏ខ្ញុំយកអង្ករមួយបាវកន្លះទៅ ដាក់ក្ដារយើងទៅ១០សន្ទឹក គ្រាន់ក្រាលផុតពីដីឲ្យកូនដេក កុំឲ្យដេកនឹងដី យកទៅគេដាក់កំណត់យើងថាអត់ឲ្យដើរទាក់ទងទៅណាមកណាទេ នៅកន្លែងណានៅតែកន្លែងហ្នឹង ហើយមានសិទ្ធិដើរតែពីកន្លែងហ្នឹងទៅបឹងទេ គេឲ្យយើងទៅមុជទឹកបឹង បន្លែ ព្រលិត កំប្លោកគេឲ្យយើងទៅបេះហ្នឹងទៅតែកុំដើរទៅលេងឯណា ទាក់ទងណា គេអត់ឲ្យមានដើរទាក់ទងណាទេ គ្រាន់តែថាគេបើកសិទ្ធិយើងទៅមុជទឹកបាន ដើរទៅបេះបន្លែក្នុងបឹងបាន តែប៉ុណ្ណឹង គេបើកផ្លូវតែប៉ុណ្ណឹងៗ អត់ហ៊ានដើរទៅទាក់ទងឯណាដូចថាផ្ទះជិតៗ គេយកយើងដាក់ឃុំហ្នឹង គេបិទសិទ្ធិកុំឲ្យដើរលេងផ្ទះគេទាក់ទងនិយាយ ដល់ថ្ងៃគេដឹកពួកប្រពន្ធៗទាហានទៅតាមប្ដី ពួកខ្ញុំក្រាញនៅគ្នា១២គ្រួសារ ក៏គេយកវិទ្យុអាគុយមកសម្ភាសន៍ពួកខ្ញុំ៣នាក់ ។

សុវណ្ណៈ ខាងណាមកសម្ភាសន៍?

នឿនៈ ពួកកូនចៅទាហានមកសម្ភាសន៍ខ្ញុំហ្នឹង ហើយប្ដីទៅផ្ដាច់ខ្លួនគេឲ្យយើងសម្ភាសន៍ថា បើឯងទៅហើយកុំវិលមកប្រពន្ធ រកកូនវិញ ព្រោះប្រពន្ធកូននៅនេះសុខសប្បាយទេ ការហូបចុកគេដោះស្រាយគ្រប់គ្រាន់ ហ្នឹងគេឲ្យពាក្យយើងនិយាយតាមគេ ហើយបើទៅហ្នឹងបានសុខហើយទៅៗរកម៉ែឪ រកបងប្អូន ទៅដល់ស្រុកស្រែហើយ គេឲ្យយើងនិយាយអីចឹង តែខ្ញុំមិននិយាយទេ ហើយកាលហ្នឹងគ្រាប់ផ្លោងមក យួនផ្លោងមក គេឲ្យយើងសម្ភាសន៍ថា បើកូនត្រូវរបួសហើយ ត្រូវគ្រាប់ផ្លោង តែកូនយើងមិនត្រូវផងៗ ត្រូវរបួសហើយគ្រាប់ផ្លោងមិនបាចបារម្ភទេ ខ្ញុំថែកូនថែចៅបាន ហើយនិងអង្គការថែឲ្យបាន យកចិត្តទុកដាក់ខាងថ្នាំលេប ថ្នាំចាក់ គេឲ្យយើងនិយាយអីចឹង តែខ្ញុំមិននិយាយទេៗ ខ្ញុំការយល់ដឹងរបស់ខ្ញុំប៉ុន្មានខ្ញុំនិយាយប៉ុណ្ណឹង ខ្ញុំអត់តាមគេទេ ខ្ញុំអត់តាមពួកវាទេ ហើយគេនិយាយចង់កូនយើងមិនត្រូវរបួស ឲ្យយើងនិយាយតាមគេចង់ឲ្យកូនត្រូវរបួស ដល់អីចឹងខ្ញុំមិននិយាយទេ

សុវណ្ណៈ កាលហ្នឹងមីងមានកូនប៉ុន្មាននាក់?

នឿនៈ ខ្ញុំកូន៣នាក់ ។

សុវណ្ណៈ ហើយគ្រួសារដែលគេចាប់ទៅមានប៉ុន្មានគ្រួសារ? ចាប់ទៅក្រោយទៀត?

នឿនៈ ៤៨ ។

សុវណ្ណៈ ៤៨គ្រួសារ?

នឿនៈ ចា៎!

សុវណ្ណៈ	សុទ្ធតែគ្រួសារដែលចុះចូល ផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាល?

នឿនៈ	៤៨គ្រួសារ ហ្នឹងសុទ្ធតែប្តីៗទៅចុះចូលខាងរដ្ឋាភិបាលយើង និងលីវៗអត់គិតទេ លីវៗដែលមកនៅជាមួយពូៗអត់គិតទេ មិនដឹងជាប៉ុន្មានទេ ប្រហែលចូល២០-៣០នាក់អត់គិតទេ គិតតែអ្នកមានគ្រួសារហើយទេ៤៨គ្រួសារ ហ្នឹងគ្រាន់តែអ្នកមានប្តី មានប្រពន្ធ ហើយអ្នកលីវៗចូលខាងទ័ពមិនដឹងប៉ុន្មានទេ ប្រហែលជា៣០នាក់ទៀតចូលជាមួយគាត់ ហើយគាត់នាំទៅទាំងអស់ ។

សុវណ្ណៈ	តាម៉ុក នាំទៅក្រោយនេះសុទ្ធតែនាំទៅប្រពន្ធទេ?

នឿនៈ	ចា៎! ប្តីទៅផ្តាច់ខ្លួន ។

សុវណ្ណៈ	នៅសល់ប្រពន្ធ អីចឹងតាម៉ុក ប្រមូលប្រពន្ធ?

នឿនៈ	ចា៎! ប្រមូលប្រពន្ធយកទៅដាក់ ។

សុវណ្ណៈ	យកទៅដាក់អន្លង់វែងដាក់នៅម្តុំណា?

នឿនៈ	ដាក់កន្លែងសាលាវែង ខាងនេះបឹង សាលារៀនវែងចេះ តែដាក់នៅអត់អស់ទេ ធ្វើផ្ទះនៅកម្ពតៗ ធ្វើខ្ទមនៅតូចៗ ដូចថាដាក់មួយគ្រែៗប៉ុណ្ណឹងខ្ទម ធ្វើខ្ទមដូចអាមេរិកអីចឹងដាក់តៗដាក់ស្បូវដណ្តបៗ ។

សុវណ្ណៈ	មិនមែនដាក់នៅភូមិទួលគ្រួសទេ?

នឿនៈ	អត់ទេ ដាក់នៅខាងលិចមន្ទីរពេទ្យចាស់យើង ។

សុវណ្ណៈ	មន្ទីរចាស់នៅអន្លង់វែង?

នឿនៈ	ចា៎! មន្ទីរចាស់នៅអន្លង់វែង ដាក់សាលារៀនអែបព្រៃខាងនោះ តែឥឡូវសាលាអស់ហើយទេដឹង ។

សុវណ្ណៈ	នៅម្តុំអូរជីកឬយ៉ាងម៉េច?

នឿនៈ	ចា៎! ម្តុំអូរជីកហ្នឹង តែមានសាលាវែងមួយ វែងមែនទែន ដល់នៅមិនអស់នាំគ្នាធ្វើខ្ទមនៅខាងៗហ្នឹងឡើងហែរទៀត ចុះមិនតិចណាលោកគ្រូ ៤៨គ្រួសារប្រពន្ធទាហាន នាំគ្នានៅហ្នឹងទៅ ។

សុវណ្ណៈ	អត់មានឃុំដាក់គុក ដាក់ច្រវ៉ាក់អីទេ? គ្រាន់តែនៅម្តុំហ្នឹងអត់ឲ្យដើរទៅណា ទៅទាក់ទងអ្នកណាទេ?

នឿនៈ	អត់មាន ដូចថាគេដាក់យើងដែរ គ្រាន់តែយើងមានកូនទៅរញ៉ៀតរញ៉ាច គ្រាន់តែគេបិទសិទ្ធិយើងមិនឲ្យដើរមានសិទ្ធិសេរីដើរលេង ដើរហើរទៅណាទៅណី គេបិទថាអត់ឲ្យដើររហេតរហូត នៅនេះអត់មានរឿងដើរ គេឲ្យយើងនៅមួយកន្លែង បើថាទៅមុជទឹកបឹងមុខឲ្យ

ដើរតាមផ្លូវមុខទៅបឹង បន្លែមាននៅហ្នឹង បន្លែមានដូចព្រលិត កំប្លោក តែមួយខែ៣០ថ្ងៃ មានកំប្លោកៗរហូត ផ្កា ត្រួយ ដៃៗ អស់ផ្កាលេងដៃ អស់ដៃលេងត្រួយ ពួកខ្ញុំ ។

សុវណ្ណៈ គេអត់មានផ្គត់ផ្គង់ម្ហូបអាហារឲ្យយើងទេ?

នឿនៈ តាំងពីខ្ញុំទៅនៅហ្នឹងឃើញគេបើកសៀង១កានចែកគ្នា ទាំងអស់៤៨គ្រួសារបើកតែ១កាន ទេតែប៉ុណ្ណឹង ក្រោយមកគេគ្មានឲ្យអីទេ យើងមានសល់លុយសល់កាក់ប៉ុណ្ណាដោះស្រាយ កាលហ្នឹងគេមានលក់ត្រី អីចឹងគេមកទៅទិញត្រីហូប ដូចថាគេបើកអង្រឹងឲ្យប្ដី គេបើកខោ អាវឲ្យប្ដី គេបើកកៅស៊ូឲ្យប្ដី គេបើកខោអាវទាហាន ស្បែកជើង ហើយមានអ្នកគេទិញ យកទៅលក់ឲ្យថៃ គេមកទិញយើងបានរបស់ហ្នឹងឯងលក់ទិញម្ហូប ទិញត្រីហូប តែត្រីកាល ហ្នឹងវាថោក ។

សុវណ្ណៈ មីងម៉េចបានខោអាវ, បានស្បែកជើង ព្រោះថាគ្រួសារមីងទៅផ្ដាច់ខ្លួនហើយ?

នឿនៈ គាត់បើកហើយគាត់ទុក ហើយយើងចេះតែទុកៗដល់ពេលបានច្រើន ដល់យើងរត់យើង ចេះតែវែកពន់ទៅ ។

សុវណ្ណៈ បានលក់របស់ហ្នឹងទៅ?

នឿនៈ ចាំ! បានលក់របស់ហ្នឹង ខ្ញុំបានរស់ព្រោះអង្រឹង ខោអាវ ស្បែកជើងប្ដី កៅស៊ូ បានលុយ កាក់ទិញម្ហូបតែអាហ្នឹង ។

សុវណ្ណៈ លក់ឲ្យខាងណាកាលហ្នឹង?

នឿនៈ ខ្មែរក្រហមដើរទិញយកទៅលក់ឲ្យថៃ ប្រុស ស្រីៗដែលចំណាស់ហ្នឹង ។

សុវណ្ណៈ យើងទាក់ទងជាមួយគេបានដែរ ព្រោះគេហាមឃាត់យើងអត់ឲ្យទាក់ទងគ្នានោះ យើងលក់ ឲ្យគេកើតដែរ ។

នឿនៈ កាលហ្នឹងអត់អីណាំថៃហើយនិងខ្មែរក្រហម ។

សុវណ្ណៈ ខ្ញុំចង់ថាមីងពេលទៅនៅអន្លង់វែង គេហាមយើងមិនឲ្យដើរទៅណា ទាក់ទងខាងណា?

នឿនៈ មានបងប្អូន ដូចខ្ញុំអីចឹងមានបង មានប្អូន សុំគេខ្ញុំចង់ទៅសួរសុខទុក្ខបងប្អូននៅក្នុងហ្នឹង គេឲ្យចូលយើងផ្ញើរទៅតាមគេ ។

សុវណ្ណៈ ម្ដុំហ្នឹងគេហៅអីគេ? ម្ដុំដែលឃុំខ្លួនគ្រួសារដែលផ្ដាច់ខ្លួន?

នឿនៈ អូរជីក ហើយអីចឹងក៏ផ្ញើរតាមគេ កាលពុកខ្ញុំនៅនោះមានអ្នកស្គាល់ ដូចថាគេចង់មកលេង គេសុំមកលេង សុំអ្នកយាមគេឲ្យចូល យើងផ្ញើរតែគេទៅ ម្នាក់មួយៗវេចក្រមាទៅវិញគេ អត់មានថាអីទេ ។

សុវណ្ណៈ	មីងកាលគេឲ្យចូលសម្អាសន៍មីងនិយាយអីគេខ្លះ? មីងអត់និយាយតាមគេ មីងនិយាយអីគេខ្លះ?

នឿនៈ	ខ្ញុំនិយាយប្ដីទៅអីចឹង បើឯងទៅដល់ស្រុកស្រែហើយ ឯងទៅផ្ទះទៅមិនបាច់វិលមករកប្រពន្ធកូនទេ ព្រោះប្រពន្ធកូននៅនេះសុខសប្បាយ ការងារធ្វើស្រែចំការបានហូបគ្រប់គ្រាន់មិនមានខ្វះហូបទេ ទៅមិនបាច់បារម្ភអីទៅនោះហើយមិនបាច់វិលក្រោយ បកក្រោយហើយកូនទាំងអស់សុខសប្បាយទាំងអស់គ្នា គ្មានកូនណាឈឺថ្កាត់ ហើយយើងភ័យខ្លាចប្ដីចូលមកយកវិញ ខ្លាចប្ដីលួចមកយកៗ ហើយខ្ញុំទោះបីមកវិញក៏ខ្ញុំមិនទៅតាមដែរ ព្រោះគេរ្ដីអាករ របស់របរ គោក្របីនៅច្រើន លោកគ្រូបើអ្នកណាទៅតាមប្ដី សូម្បីតែមកវិញដីមួយដុំក៏គេយកអស់ដែរ ទៅគេយកអស់ហើយគ្មានសល់ទេៗ ឯចំណែកខ្ញុំអត់ទៅតាមប្ដីគេរ្ដីអាករ ស្រែចំការ នៅសល់ច្រើន របស់របរក៏នៅសល់ច្រើន ប្រើប្រាស់គ្រប់គ្រាន់រទេះ គោ ស្រូវនៅពេញៗផ្ទះ ហូបស្រួល មាន់ទា អ្នកដែលតាម៉ុក ដឹកទៅតាមប្ដីមកវិញសូម្បីតែដីភូមិផ្ទះក៏មិនមាននៅដែរ គេយលអស់អ្នកនៅហ្នឹងគេយកអស់ ហើយអ្នកទៅមិនមែនថាទៅហើយវិលវិញភ្លាមៗណា ទៅមាន១ឆ្នាំ ឬ៥-៦ខែ ហើយនេះគេរំដោះបានអ្នកនៅនេះគេយក ដល់អ្នកនៅគេយកគេមិនឲ្យវិញ មកគេមិនឲ្យ ហើយអ្នកគ្នាទៅហើយមកយកវិញមិនឲ្យ ដូចដីភូមិធំអីចឹង គេឲ្យត្រឹមដីយើង៤០-៥០ម៉ែត្រគេឲ្យតែ១០ម៉ែត្រនៅតែប៉ុណ្ណឹង ទៅតវ៉ាតមិនបាន មានតែខ្ញុំទេក្រាញនៅ១២គ្រួសារហ្នឹង ទ្រព្យច្រើនជាងគេ មានគោក្របីនៅទាំងអស់ រទេះនៅទាំងអស់គ្មានពីណាគេកេងប្រវ័ញ្ចៗ គ្រាន់តែបេញផុតលោកគ្រូអើយគេអ្នកនៅ គ្រាន់តែគេយកខ្ញុំទៅដាក់ឃុំឃាំងនៅអន្លង់វែង គ្រាន់តែបេញផុតម្នាក់ៗចង់បានទ្រព្យយើង ខ្លះគេថាខ្ញុំជំពាក់អង្ករគេ១បេ គេយកស្រូវ២បាវ ខ្លះគេថាខ្ញុំជំពាក់លុយគេ៣ម៉ឺន គេយកក្បាលកិន ខ្លះគេថាខ្ញុំខ្ចីលុយគេ៥ម៉ឺន គេមកអូសរឺបរទេះ រទេះយើងតម្លៃ២០-៣០ម៉ឺនគេយកទៅ ដល់ទទួលដឹងដំណឹងខ្ញុំមកវិញ ម្នាក់ៗមកសុំទោស លោកគ្រូខ្ញុំមនុស្សចេះដឹងតិចតួចដែរ គេនិយាយអីខ្ញុំបិទមាត់គេរហូត ខ្ញុំថាកុំនិយាយអីប៉ះពាល់គេ មិនដឹងទេយើងនិយាយមួយម៉ាត់ចូលត្រចៀកគេ គេចាប់សំដីយើងហ្នឹងថាយើងមិនមែនគេទេ គេអ្នកផ្សេងទៀត បានខ្ញុំថាពួកខ្ញុំទៅជាមួយខ្ញុំ រត់មកជាមួយខ្ញុំគ្រាន់តែគេកៀរឡើងភ្នំដងរែក កៀរប្អូនៗគេ ខ្ញុំក្ដាប់បានគ្នា៥គ្រួសារ ខ្ញុំទៅប្រាប់ថាឯងកុំទៅអី ឥឡូវឯងកុំទៅអី គេអ្នកមានគោយន្ត គេអ្នកមានរទេះគេទៅអស់ ប្រុសៗគេដឹកអង្ករ ដឹកស្លឹកគ្រៃសំរាប់កូនចៅគេហូប ហើយយើងស្ពាយនឹងស្នារ គ្មានអ្នកបរ គ្មានពីណារែក គ្មានពីណាលី ហើយយើងទៅម្នាក់អង្ករមួយទៃៗ យើងហូបបានប៉ុន្មានពេល ហើយ

ហូបបានប៉ុន្មានថ្ងៃ ឥឡូវមិត្តឯងវិលទៅវិញ ទៅភូមិវិញ បើគេសួរតាមផ្លូវយើងប្រាប់គេថាខ្ញុំវិលទៅយកគោ រទេះខ្ញុំដឹកអង្ករ ដឹកស្ទីកគ្រែទៅហូប ខ្ញុំឡើងទៅស្ពាយអង្ករមួយថៃនេះមិនដឹងហូបបានប៉ុន្មានពេលទេ កូនសាប់អស់ ល្មមតែអង្ករបើកអង្ករឲ្យហូបទៅមិនដឹងដោះស្រាយម៉េចបាន អីចឹងហើយខ្ញុំកៀរបាន៩គ្រួសារមក មកដល់ពួកដែលនៅគេថាកៀរឡើងភ្នំគ្រាន់តែឃើញខ្ញុំមកកៀរបាន៩គ្រួសារ ពួកហ្នឹងមកតាមខ្ញុំដែរ អត់នៅ ដល់មកតាមខ្ញុំខ្ញុំគ្រាន់តែឃើញឡានតាជឿន គ្រាន់តែឃើញមកខ្ញុំលើកដៃតាសុំឡានផង ហើយមេកងពលធំ ។

សុវណ្ណៈ កងពលលេខប៉ុន្មានមីង តាជឿន?

នឿនៈ កងពលលេខប៉ុន្មានលេខ៨ ហើយគេស្ទើចខ្ញុំថាហ៊ានសុំឡានមេជិះ ខ្ញុំថាខ្វាចអីដំណាក់កាលហ្នឹង បើយកខ្ញុំទៅសម្លាប់ចោលក៏សម្លាប់ទៅដំណាក់កាលនេះហើយ ។

សុវណ្ណៈ តាជឿន ហ្នឹងខាងខ្មែរក្រហម ឬខាងរដ្ឋាភិបាល?

នឿនៈ ខាងខ្មែរក្រហមតែមេកងពល កងពលគាត់ឈប់ឲ្យខ្ញុំជិះ ឃើញម្នាក់ទៀតដើរពីក្រោយខ្ញុំខ្ញុំថាមកឲ្យលឿនជិះឡាន២នាក់ បាន២គ្រួសារ បងអើយឲ្យគេឈប់ត្រង់ហ្នឹងហើយយើងដើរក្នុងព្រៃវិញទៅខ្លាចគេ ខ្ញុំថាដំណាក់កាលនេះហើយអត់ខ្លាចទេ ខ្ញុំអត់មានរឿងខ្លាចអៀនទៀតទេដំណាក់កាលប៉ុណ្ណេះហើយ ខ្ញុំគ្មានខ្លាចអៀនទេ មកដល់កន្លែងផ្លូវចូលផ្ទះចេះដូចថាផ្លូវបំបែកចូលផ្ទះខ្ញុំឲ្យគេឈប់ បងអើយឈប់ត្រឹមហ្នឹងនេះផ្លូវចូលផ្ទះខ្ញុំ គេឈប់ឡានខ្ញុំចុះ គ្រាន់តែខ្ញុំលើកវ៉ាឡូពីឡានស្ពាយ កូនក្មេងតូចៗចេញមកតាមថ្នល់ ថ្នល់មុខផ្ទះខ្ញុំអីចឹងគ្រាន់តែក្រឡេកឃើញខ្ញុំស្ពាយវ៉ាឡូ និយាយពីមនុស្សចេញទាំងចាស់ ទាំងក្មេង ឲ្យក្រេវមក ប្រពន្ធអ៊ំយុងមកវិញហើយៗ គេអរគ្រប់គ្នា ដល់មកដល់ផ្ទះគ្រួសារខ្ញុំគេមក ឯងនៅណា នៅផ្ទះហ្នឹងខ្ញុំវិលមកវិញហើយ ឯងនៅផ្ទះស្មានតែឯងអត់នៅ បើថាឯងអត់នៅគេកៀរឡើងភ្នំអស់ អញតែទៅដល់កូនក្មេងដេកអង្រឹងក៏អញសម្លាប់ឯងចោលអស់ពួកក្បត់សម្លាប់ខ្មែរគ្នាឯង តាខ្ញុំ ហើយតាហ្នឹងស្លូតណាស់គាត់មិនដែលថាទាហានណាស្អប់ទេបំណែកតែគាត់ស្ពាយលុយមួយវ៉ាឡូហើយ យកទៅប្រគល់ឲ្យមេកងពលវិញទាំងអស់ ដល់អត់ថ្នាំជក់សុំគេតែ៥ពាន់គេមិនឲ្យវិញផង ហើយមិនដែលលឺមាត់មួយអីសតាខ្ញុំ ហើយគេអ្នកទាហានៗដូចគ្នា គេក្បត់ពីគាត់ ឬក្បត់ពីមេធំ ថាឲ្យតាហ្នឹងឃ្លានពីគេតែ៣ម៉ែត្រ ដើរគាត់ព្រៃគេសម្លាប់ចោលយកលុយ មានអ្នកគេប្រាប់ទៀត បងឯងស្ពាយលុយកុំដើរឆ្ងាយពីគេ គាត់ដឹងដើរមិនហ៊ានឃ្លាតពីគេទេ ត្រង់ណាមនុស្សច្រើនគាត់ដើរត្រង់ហ្នឹង ហើយតាខ្ញុំសក្តិ៤ដែរ ។

សុវណ្ណៈ ឥឡូវ?

នឿនៈ ឥឡូវគាត់កាត់ហើយ ។

សុវណ្ណៈ ចូលនិវត្តន៍ហើយ?

នឿនៈ គាត់កាត់ឡើង២ឆ្នាំហើយ រាល់តែឆ្នាំខ្ញុំធ្វើស្រែចំការ ចិញ្ចឹមកូនតែឯងមួយខែទល់មួយខែ មួយឆ្នាំទល់មួយឆ្នាំនៅតែប្រាសាទព្រះវិហារ មិនដែលបានមកជួយធ្វើស្រែ ធ្វើចំការខ្ញុំទេ តែខ្ញុំមិនភ្ជួរគោយន្តដូចឥឡូវទេ ខ្ញុំភ្ជួរគោ គោខ្ញុំលិចៗក្បាល ព្រលឹមឡើងងងឹតឡើងខ្ញុំបរគោពីមុខមួយ ពីក្រោយមួយ នង្គ័លលី យកទៅភ្ជួរខ្លួនឯង សាបក៏ខ្លួនឯង ដកស្ទូងរែកកណ្តាប់ក៏ខ្លួនឯង ច្រូតក៏ខ្លួនឯង ភ្ជួររាស់ក៏ខ្លួនឯង មិនដែលប្តី២ឆ្នាំនៅតែមុខមិនដែលបានជួយទេ ខ្ញុំប្រុសផង ស្រីផង ដល់ពេលច្រូតហើយបោកខ្លួនឯងទៀត រែកពន់ទូលតែខ្លួនឯង មិនមានគោយន្ត មិនមានរទេះដឹកដូចឥឡូវទេ ។

សុវណ្ណៈ មីងកាលហ្នឹងខាងរដ្ឋាភិបាលចូលវៃតាម៉ុក ចូលវៃឆ្នាំណា? ដែលចូលវៃហើយមីងបកមកនៅនេះវិញ កាលហ្នឹងឆ្នាំណា?

នឿនៈ ខ្ញុំមិនបានគិតដែរ ។

សុវណ្ណៈ ដែលតាម៉ុក កៀរប្រជាជនឡើងភ្នំហើយមីងអត់តាមកាលហ្នឹងឆ្នាំណា?

នឿនៈ ខ្ញុំវាភ្លេចកន្លែងហ្នឹង បើតាបានដឹងច្បាស់ គាត់គិតគ្មានខុសទេ រត់ពីចិតប៉ុន្មាន វិលមកកៅប៉ុន្មានគាត់ដឹងទាំងអស់ តែខ្ញុំវាចេះតែភ្លេច មិនបានគិត ។

សុវណ្ណៈ មីងត្រឡប់ពេលដែលរដ្ឋាភិបាលចូលវៃទ័ពតាម៉ុក មីងក៏ត្រឡប់មកភូមិវិញមក?

នឿនៈ ចា៎! មកនៅភូមិដល់គេរំដោះបានខ្ញុំមកនៅភូមិចាស់វិញ ភូមិខ្លួនឯងចាស់ពីមុនមក បើសិនណាភូមិខ្ញុំមកនៅតាំងពីអើយ តាំងពីជំនាន់តាសារឿន ផាប់បើថាដើមដូងចង់ផាប់ទៅវិញ ដាំតែដុតពីក្បាល ដើមស្វាយដាំដុតពីក្បាលរត់ចេញបាត់ ភ្លើងឆេះ បើថាអំពៅជុំវិញផ្ទះចង់ហូបមួយថ្ងៃ២០-៣០ដើមក៏មិនអស់ ដាំនោះដាំ ។ ចុះការជំនាន់នោះភូមិ-ឃុំដែនការគេឲ្យដាំ ដែនការ១០ថ្ងៃ ក្នុងមួយថ្ងៃគេកំណត់ឲ្យយើងដាំដំឡូង៥គុម្ព អំពៅ៥គុម្ពក្នុងមួយថ្ងៃ គេឲ្យដាំ ហើយហ្នឹងគេដាក់ដែនការ១០ថ្ងៃ ស្អីក៏ដោយគេឲ្យយើងដាំ៥ៗគុម្ព ដំណាំខ្លះឲ្យដាំ១-២គុម្ព ដូចជាស្វាយ ដូង ១-២ដើម បើថាក្រៅពីហ្នឹងដូចជាចេក អំពៅ ល្ហុង ដំឡូងឈើ ដែនការ១០ថ្ងៃគេឲ្យដាំ៥ដើមគ្រប់មុខ ។

សុវណ្ណៈ ខ្ញុំចង់បកក្រោយបន្តិចកាលហ្នឹងមូលហេតុអីមីងចូលបដិវត្តន៍ជាមួយគេ យើងចូល៧/២មូលហេតុអីចូលជាមួយគេ?

នឿនៈ ចូលធ្វើ ។

សុវណ្ណៈ កាលហ្នឹងចូលធ្វើបដិវត្តន៍កាលហ្នឹងនៅព្រៃវែង?

នឿនៈ ចេះទេបានខ្ញុំចូល ខ្ញុំវាក្រពេកអត់មានដី ហើយដូចថាខ្ញុំអីចឹង ក្រុមគ្រួសារមាន៤នាក់ គេមាន២នាក់ឬ៣នាក់ ដល់គេចែកដីគេចែកឲ្យស្មើនឹងខ្ញុំ ដល់អីចឹងខ្ញុំឈឺចាប់ នឹកថាខ្លួនឯងក្រុមគ្រួសារឯង៤នាក់ គេ៣នាក់ចែកដីស្មើនឹងឯង៤នាក់ គេ២នាក់ ឯង៤នាក់ចែកស្មើនឹងឯង៤នាក់ដែរ ខ្ញុំខឹងចិត្តខ្ញុំថាតោះតាមិនបាច់នៅហ្នឹងទៀតទេ យើងលក់ខ្ទមហ្នឹងទៅ ធ្វើសោហ៊ុយដើរទៅនៅស្រុកគេទៅ ប្រវត្តិយើងសំរាប់ធ្វើទាហាន ឲ្យធ្វើមួយជីវិតហ្នឹងទៅខ្ញុំថាអីចឹង នាំប្តីប្រពន្ធចេញពីស្រុកមកនៅព្រៃខ្មែរក្រហមហ្នឹងរហូត ទាល់តែផ្តាច់ខ្លួនហ្នឹងបានឈប់ ហើយផ្តាច់ខ្លួនខ្ញុំមិនដែលជុំគ្នា មួយឆ្នាំទល់មួយឆ្នាំ ពីរឆ្នាំទល់ពីរឆ្នាំ មិនដែលបានជុំគ្នាទេ ។

សុវណ្ណៈ ខ្ញុំចង់និយាយចេះកាលហ្នឹងមីងចូលបដិវត្តន៍ជាមួយតស៊ូដំបូង៧២ត្រូវទេមីង?

នឿនៈ ចា៎! ៧២ ។

សុវណ្ណៈ កាលហ្នឹងមីងនៅក្មេង មីងចូលជាមួយគេ មូលហេតុអីមីងចូលជាមួយគេ ដឹងមូលហេតុទេ?

នឿនៈ កាលហ្នឹងដូចគេឃោសនាឲ្យយើងចូលធ្វើអីចឹង ហើយកាលហ្នឹងក្មេងវាចិត្តចង់សប្បាយ វាមានគ្នាស្រីៗច្រើនអីចឹងទៅ គេណែនាំយើងពីការធ្វើការងារ យើងបាក់ចិត្តចូលនឹងគេ ។

សុវណ្ណៈ គេឃោសនា?

នឿនៈ ចា៎! ឃោសនាឲ្យយើងចូលធ្វើយុទ្ធនារី ឬយើងធ្វើនារីដឹកជញ្ជូន ហើយក្មេងវាឈាមរាវចិត្តវាចង់ខាងហ្នឹងទៅតាមគេ ។

សុវណ្ណៈ មីងចូលទាំងបង្ខំ ឬស្ម័គ្រចិត្តទេ?

នឿនៈ កាលហ្នឹងស្ម័គ្រចិត្តតែលោកពុកយាំងតែនៅតែខ្ញុំទៅ មិនយូរទេប្រហែល៥ខែវិលមកវិញ ។

សុវណ្ណៈ វិលមកផ្ទះវិញ?

នឿនៈ ចា៎!

សុវណ្ណៈ មុននឹងចូលឪពុកមីងឃាត់?

នឿនៈ ឃាត់ ។

សុវណ្ណៈ ឃាត់ថាម៉េច?

នឿនៈ គាត់ថាមិនដឹងទៅធ្វើអីកូនអើយស្រីញីដើរដេកតាមព្រៃ វាមិនសម ដល់ពេលយើងចិត្តចង់ក៏ទៅដល់មានការលំបាកក៏វិលមកវិញ ។

សុវណ្ណៈ លំបាកហ្នឹងលំបាកម៉េចខ្លះ?

នឿនៈ លំបាកហ្នឹងការហូបចុក ការដេកនៅ ដើរយប់ព្រលប់ ហើយនៅក្មេងថាដេកវាពាន់ត្រូវ ហើយយើងដើរវាមិនត្រូវ មិនវិល ដេកដូះស្រួល ដេកព្រៃលំបាកត្រូវខ្យល់ ត្រូវសន្សើម

សុវណ្ណៈ ដល់ពេលយើងមកវិញគេឲ្យមកដែរ?

នឿនៈ ឲ្យមកមានអី យើងថាក្រាញមិនព្រមនៅថានឹកម៉ែ នឹកឪ នឹកបងប្អូន អីចឹងគេមិនបង្ខំទេ តាមយើងស្ម័គ្រចិត្ត អត់មានគេធ្វើបាបយើងដែរតាមចិត្តយើង ចិត្តយើងចង់ធ្វើ មិនចង់ អ្នកគេចង់ចេះតែទៅមុខ អ្នកគេមិនចង់វិលមកវិញ ។

សុវណ្ណៈ អីចឹងក៏ត្រឡប់មកវិញ អត់មានមកធ្វើអីទេ?

នឿនៈ ចាំ!

សុវណ្ណៈ នៅរហូតដល់ខ្មែរក្រហមគេវ៉ៃបែកភ្នំពេញ?

នឿនៈ អត់ទេ ។

សុវណ្ណៈ នៅរហូតដល់ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិតែម្តង ឬយើងចូលទៅម្តងទៀត?

នឿនៈ ខ្ញុំនៅរហូតទល់គេរើសឲ្យធ្វើខាងកងចល័តបានទៅ១ឆ្នាំ បានគេទៅយកពីកងចល័តឲ្យមកធ្វើគ្រូ ។

សុវណ្ណៈ ចុះពេលខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេសគេមានជម្លៀសមីងទៅណា? គេជម្លៀសអ្នកដូះមានទេមីង?

នឿនៈ គេជម្លៀសដែរ ។

សុវណ្ណៈ គេជម្លៀសចេញពីភូមិយើង?

នឿនៈ ចាំ! គេជម្លៀសចេញពីភូមិឲ្យទៅនៅភូមិផ្សេង ។

សុវណ្ណៈ ភូមិអីគេភូមិផ្សេងហ្នឹង?

នឿនៈ ខ្ញុំជម្លៀសពីភូមិចំរេះទៅនៅភូមិថ្មីង ។

សុវណ្ណៈ ជម្លៀសទាំងឪពុកម្តាយ?

នឿនៈ ចាំ! ជម្លៀសទាំងអស់ភូមិថ្មីងក្បែរព្រំដែនយួន គេយកពីកណ្តាលស្រុកទៅគេឲ្យទៅនៅព្រំដែន គេយកពីព្រំដែនឲ្យមកនៅកណ្តាលស្រុកវិញ ។

សុវណ្ណៈ អីចឹងបានថានៅក្នុងស្រុកកំពង់ត្របែកដែលទេ?

នឿនៈ ចាំ! នៅក្នុងហ្នឹងដូចគ្នា ។

សុវណ្ណៈ គ្រាន់តែនៅក្នុងភូមិផ្សេង?

នឿនៈ ចាំ! នៅភូមិផ្សេង ។

សុវណ្ណៈ អីចឹងមីងមុនដំបូងនៅកណ្តាលស្រុក ក្រោយមកឲ្យទៅនៅខាងព្រំដែន?

នឿនៈ ដូចថាគេអ្នកនៅព្រំដែនអីចឹងទៅ គេជ្រួតជ្រាបច្បាស់លាស់ពីយួន គេចេញចូលរកស៊ីជាមួយយួនកន្ទង់មក ដែលគេធ្លាប់នៅកន្ទង់មក ដល់អីចឹងគេយកអ្នកនៅព្រំដែន គេជម្លៀសឲ្យនៅកណ្តាលស្រុក ហើយគេយកពីអ្នកកណ្តាលស្រុកឲ្យទៅនៅតាមព្រំដែនវិញ ។

សុវណ្ណៈ សព្វថ្ងៃនេះមីងធ្លាប់ទៅលេងផ្ទះ?

នឿនៈ ខ្ញុំទៅ ។

សុវណ្ណៈ ទៅលេងផ្ទះ ទៅលេងឆ្នាំណា? ទៅលេងបងប្អូន?

នឿនៈ ខ្ញុំទៅលេងបងប្អូនបែកហើយខ្ញុំទៅម្តង ទៅយកប្អូនពៅដើរម៉ិញ ខ្ញុំទៅយកវាមក ។

សុវណ្ណៈ ទៅយកនៅខាងព្រៃវែង?

នឿនៈ ហ្នឹងហើយទៅយកខាងព្រៃវែងដែរ ទៅខាងព្រំដែនយួនដែរ នៅខាងត្បូងត្របែកក្បាលថ្នល់ យើងនៅខាងជ័យគា ។

សុវណ្ណៈ ទៅគេស្គាល់ដែរ?

នឿនៈ ស្គាល់ ។

សុវណ្ណៈ យើងចេញមកវាងធំដែរ?

នឿនៈ ចាំ!

សុវណ្ណៈ ហើយធ្វើម៉េចយើងទៅកើត? សមាហរណកម្មហើយ ឬមុនសមាហរណកម្មពេលទៅលេងបងប្អូនមីង?

នឿនៈ សមាហរណកម្មហើយ ខ្ញុំទៅស្មោងហើយបានទៅយកប្អូនមកហ្នឹង ដល់ពេលក្រោយមកខ្ញុំឆ្នាំទៅខ្ញុំទៅធ្វើបុណ្យឲ្យម៉ែស្រុកខ្ញុំនោះ ឆ្នាំទៅមួយខ្ញុំទៅធ្វើបុណ្យម៉ែនេះ ខាងជើងឈើកាច់កូនដែក គ្រួសារខ្ញុំនៅខាងកូនដែក ខ្ញុំនៅខាងជ័យគា ស្រុកកំណើត ។

សុវណ្ណៈ មីងចេះមីងខសប្បាហ៍ទៅលេងផ្ទះឥឡូវ?

នឿនៈ ខ្ញុំទៅរាល់ឆ្នាំដែរ ។

សុវណ្ណៈ តែឪពុកម្តាយខូចអស់ឆ្នាំនេះឬនៅដែរ?

នឿនៈ ខូចអស់ ខូចទាំងអស់គ្នា ទាំងខ្ញុំទាំងតាខ្ញុំ ។

សុវណ្ណៈ ឪពុកមីងឈ្មោះអីគេ?

នឿនៈ ឪពុកខ្ញុំឈ្មោះ ភុន នាង ។ ម៉ែឈ្មោះនាង ឪពុកឈ្មោះភុន ។

សុវណ្ណៈ ឪពុកឈ្មោះអីគេ?

នឿនៈ ឈ្មោះភុន ។

សុវណ្ណៈ ឈ្មោះពេញអីគេភុន? មីងត្រកូលសួន នឿន?

នឿនៈ ឪខ្ញុំ ខ្ញុំយកជីតាដាក់។

សុវណ្ណៈ អីចឹងឪពុកឈ្មោះអីគេ ភុន?

នឿនៈ ឈ្មោះ សួន ភុន។

សុវណ្ណៈ ដាក់សួន ភុន ឬអត់ទេ?

នឿនៈ សួន ភុន។

សុវណ្ណៈ គាត់ឈ្មោះសួន ភុន?

នឿនៈ ចាំ! សួន ភុន ម្ដាយឈ្មោះ រ៉ា នាង។

សុវណ្ណៈ រ៉ា?

នឿនៈ រ៉ា នាង។

សុវណ្ណៈ គាត់ខូចឆ្នាំណាឪពុកមីង?

នឿនៈ ឪពុកខ្ញុំខូច៥ឆ្នាំហើយ។

សុវណ្ណៈ ក្រោយៗទេ?

នឿនៈ ចាំ?

សុវណ្ណៈ ទើបតែខូចក្រោយៗនេះទេ?

នឿនៈ ចាំ! ទើបតែខូចក្រោយ។

សុវណ្ណៈ ចុះម្ដាយ?

នឿនៈ ម្ដាយខ្ញុំខូចមុនឪពុកខ្ញុំបាន២ខែ ៥ឆ្នាំដូចគ្នាតែបាន២ខែ។

សុវណ្ណៈ បងប្អូននៅជុំគ្នាទាំងអស់ ឬក៏មានអ្នកខូចខ្លះហើយ?

នឿនៈ ខ្ញុំបាត់មួយ បាត់ប្អូនស្រីមួយ។

សុវណ្ណៈ បាត់ដំណឹងឬក៏ស្លាប់តែម្ដង?

នឿនៈ បាត់តែម្ដង មិនដឹងរស់ មិនដឹងងាប់ បាត់តែម្ដង។

សុវណ្ណៈ បាត់ដំណឹងប្អូនស្រីមួយ?

នឿនៈ ចាំ! បាត់ប្អូនស្រីមួយ។

សុវណ្ណៈ បាត់ហ្នឹងយើងបាត់ពីពេលណាមក?

នឿនៈ បាត់ហ្នឹងតាំងពីយើងនៅខ្មែរក្រហម នៅឯភូមិថ្មីងនៅក្បែរព្រំដែន។

សុវណ្ណៈ កាលហ្នឹងគេឲ្យប្អូនធ្វើអីគេ?

នឿនៈ កាលហ្នឹងគេឲ្យវាទៅរោងចក្រ។

សុវណ្ណៈ ហើយអត់បានដំណឹងទាក់ទងគ្នារហូតមក?

នឿនៈ ចាំ! ដល់ពេលទៅបានតែមួយអាទិត្យឃួនចូលដល់ ក៏រត់អាគាត់អាគាយមិនដឹងទៅណាទៅណី បាត់ដំណឹងរហូតដល់ថ្ងៃនេះ ។

សុវណ្ណៈ មានដែលស៊ើបសួររកប្អូនខ្លះទេ ។

នឿនៈ ខ្ញុំអត់ដែលស៊ើបផង ខ្ញុំថាដាក់ពាក្យសួររកដែរ មិនទាន់បានដាក់ ។

សុវណ្ណៈ បើថានេះខ្ញុំជួយសួររកដំណឹងប្អូនស្រីជូនឲ្យ ។

នឿនៈ ចាំ! មានអីបើគាត់ជួយខ្ញុំអរគុណច្រើន ។

សុវណ្ណៈ អីចឹងចាំខ្ញុំសួររកន្លែងហ្នឹងតាមក្រោយ ។ មីងចេះសព្វថ្ងៃមីងពេញចិត្តជីវិតរស់នៅពេលបច្ចុប្បន្ននេះ?

នឿនៈ ចាំ! ពេញចិត្ត ។

សុវណ្ណៈ មូលហេតុអីមីងពេញចិត្ត?

នឿនៈ មូលហេតុដែលខ្ញុំពេញចិត្ត កន្លងមកដែលខ្ញុំធ្លាប់លំបាក បែកបងប្អូន ម៉ែ ប្ដីសី ហើយមកដល់បច្ចុប្បន្ននេះនៅជួបជុំបងប្អូន ប្ដីសី ដេកស្រួល ហូបស្រួល ដើរស្រួល ចង់ទៅណាមកណាស្រុកគេឆ្ងាយជិតអីបានគ្រប់បែបទាំងអស់ ដល់អីចឹងហើយខ្ញុំពេញចិត្ត ហើយម្យ៉ាងទៀតនឹកឃើញថារដ្ឋាភិបាលយើង មើលឃើញវាភ្លឺទៅមុខ ដូចថាប្រជាជនខ្វះខាត ដូចជាទឹកលិចរដ្ឋាភិបាលជួយជាផ្ទះសំបែង ជាអង្ករ ស្លឹកគ្រៃ សំលៀកបំពាក់ កន្ទេល ខ្នើយដេក សំរាប់ដោះស្រាយជីវិតយើង អាហ្នឹងម្យ៉ាង ម្យ៉ាងទៀតរដ្ឋាភិបាលដោះស្រាយដូចថាយើងធ្លាប់ដើរផ្លូវលំបាក កូនចៅរៀនគ្មានសាលារៀន ហើយរដ្ឋាភិបាលកសាងសាលារៀនក្មេង កូនចៅ ហើយផ្លូវដើរស្រួលជិះឡានម៉ូតូ ហើយមិនលំបាកទៅណាមកណា ដឹងរហូតដល់អីចឹងហើយខ្ញុំពេញចិត្ត សប្បាយ កន្លងមកខ្ញុំធ្លាប់លំបាក ដល់ឃើញស្រួលអីចឹងខ្ញុំគិតតែពីសប្បាយ ដូចថាក្នុងចិត្តចង់ទៅលេងស្រុកទៅស្រួល មកក៏ស្រួលវាមិនលំបាកដូចមុន ។

សុវណ្ណៈ ចុះពីមុនលំបាកយ៉ាងម៉េចមីង?

នឿនៈ ពីមុនលំបាកដូចថាយើងដើរផ្លូវ ចុះខ្ញុំផ្ដាច់ខ្លួនភ្លាមខ្ញុំទៅដើរពីហ្នឹងដេកផ្លូវឡើង៣យប់៣ថ្ងៃបានខ្ញុំទៅដល់បន្ទាយស្រី ខ្ញុំទៅឡើងឡានបន្ទាយស្រី ខ្ញុំទៅដេកបន្ទាយស្រីមួយយប់បានជួលឡានគេឡើងទៅភ្នំពេញ ។

សុវណ្ណៈ ហ្នឹងយើងសមាហរណកម្មហើយទេ?

នឿនៈ ចាំ!

សុវណ្ណៈ ចុះមិនទាន់សមារណកម្មកាលយើងនៅតស៊ូ លំបាកយ៉ាងម៉េចខ្លះ?

នឿនៈ នៅតស៊ូលំបាកដូចថាយើងដើរទៅណាមកណា យើងដើរតែនឹងជើង កង់ក៏មិនមានជិះ មានតែរទេះដឹក រទេះដឹកទឹមគោ គ្មានកង់ គ្មានម៉ូតូ មានតែគេអ្នកមាន ដែលមេៗគេមានគោយន្តបើក គេមានឡាន មេៗគេ។

សុវណ្ណៈ អ្វីជាផលវិបាកសំរាប់មីង កាលនៅតស៊ូ?

នឿនៈ ខ្ញុំលំបាកជាងគេបែកប្តី ធ្វើស្រែចំការ កាប់ព្រៃយកដីដាំស្រូវម្នាក់ឯង។

សុវណ្ណៈ ចុះយើងត្រូវរត់ចុះឡើង រត់កាត់គ្រាប់?

នឿនៈ ពេលណារត់ទៀតស្ពាយអង្ករ ខោអាវ ចានឆ្នាំងតែម្នាក់ឯងរែកពន់តែម្នាក់ឯង ហើយកូននៅតូចៗ ដល់អីចឹងវាលំបាក។

សុវណ្ណៈ ដល់ពេលបច្ចុប្បន្ននេះមីងមានអីអត់ពេញចិត្តខ្លះទេ? ចំពោះការរស់នៅបច្ចុប្បន្ននេះមានអីមីងអត់ពេញចិត្ត?

នឿនៈ អត់មាន បច្ចុប្បន្នក្នុងរដ្ឋាភិបាល?

សុវណ្ណៈ បាទ! ឥឡូវ។

នឿនៈ អត់មាន មានតែបងប្អូនយើងនៅក្នុងភូមិ មិនមែនតែបងប្អូនសាច់ឈាមយើងទេ ដែលគេចុះចូលខាងគណបក្សផ្សេង ខ្ញុំពន្យល់គេ ពន្យល់គេថាមុននឹងឯងចូលគណបក្សផ្សេងយើងសំលឹងមើលឲ្យវែងបន្តិចសិនទៅ តើអ្នកណារីកចំរើន អ្នកណាមិនរីកចំរើន ខ្ញុំថាអីចឹងព្រោះរដ្ឋាភិបាលយើង យើងមើលឲ្យវែងបន្តិចទៅ រដ្ឋាភិបាលយើងកន្លងមកតើរដ្ឋាភិបាលយើងអនុវត្តន៍អីខ្លះឲ្យយើង ហើយជួយស្អីខ្លះឲ្យយើង យើងត្រូវគិត ឥឡូវអ្នកមានហើយនិងអ្នកក្រតើអ្នកឯងជ្រើសរើសយកអ្នកណា ខ្ញុំថាអីចឹង អ្នកមានគេមានខ្លាំងហើយគេសល់គេហូរមកដល់យើង ចុះអ្នកក្រដែលយើងទើបតែឲ្យក្រោយតើគេឲ្យហូរមកដល់យើងទេ? គេទុកផ្គប់ផ្គុនតែក្រុមគ្រួសារគេហៀរហូរ តើប៉ុន្មានឆ្នាំបានហៀរហូរខ្ញុំថាអីចឹង មិនងាយហៀរហូរទេ ឥឡូវយើងគិតទៅ? អ្នកដែលហៀរហូរមុនយើងត្រូវទ្រាំទ្រ យើងគិតទៅគាត់ ហើយគាត់ជួយយើងច្រើនណាស់ ជួយមួយចប់តែម្តង។ ហើយរាល់ថ្ងៃអូនពីណាមកឃោសនាខ្ញុំ ឲ្យឃោសនាដល់ងាប់ទៀតខ្ញុំអត់ជឿ។

សុវណ្ណៈ ម៉េចអីចឹងមីង?

នឿនៈ ចាំ?

សុវណ្ណៈ ម៉េចអត់ជឿអីចឹង?

នឿនៈ ខ្ញុំមិនជឿ បើខ្ញុំឃើញហើយ ខ្ញុំមើលទៅឃើញច្បាស់លាស់របស់ខ្ញុំហើយ ឲ្យខ្ញុំជឿយ៉ាងម៉េចបាន ខ្ញុំមិនជឿទេ ទោះបីនៅខ្មែរក្រហមក៏ដោយច្បាប់វាតឹងបំផុត ខ្ញុំហ៊ានតវ៉ា ហ៊ាន

តវ៉ាអី? ដូចអ្នកឯងនិយាយមកមិនសមរម្យ ចូលក្នុងច្បាប់ ក្នុងទំលាប់ ខ្ញុំហ៊ានតវ៉ា ខ្ញុំហ៊ានប្រឆាំង ហើយខ្ញុំបណ្ដេញទៀតអ្នកឯងទៅប្ដឹងឯណាទៅប្ដឹងទៅ ព្រោះខ្ញុំនិយាយក្នុងច្បាប់ ខ្ញុំអត់មាននិយាយក្រៅច្បាប់ទេ តែឯងដែលនិយាយក្រៅច្បាប់ ខ្ញុំអត់ខ្លាច ខ្ញុំអត់ខ្លាចទេ ចំណែកក្នុងប្រជុំមេកងពលចាប់ចំណុចយើងថា យើងខុសចេះមួយ ចុះមួយ ខ្ញុំហ៊ានតវ៉ា ខ្ញុំអត់ខ្លាចទេ ខ្ញុំថាតវ៉ាបើខ្ញុំអ្នកធ្វើខ្ញុំមិនខ្លាច បើអ្នកឯងធ្វើខ្ញុំដែលខ្លាច ខ្ញុំថា យើពួកឯងធ្វើអីបានត្រឹមតែបញ្ជារគេហ្នឹង បើពួកឯងកសាងគេ ពួកឯងកសាងខ្លួនឯងសិនទៅចាំកសាងគេ ខ្ញុំមើលទៅពួកឯងបានត្រឹមបញ្ជារគេ បើពួកឯងមិនអនុវត្តន៍ខ្លួនឯង ដៃនៅស្មៀមសោះ បើដៃគេឡើងរវើក ខ្ញុំថាអីចឹង ថាខ្ញុំមិនខ្លាចទេ ខ្ញុំនិយាយខ្ញុំគិតសិន។

សុវណ្ណៈ សព្វថ្ងៃមីងនៅភូមិយើងមានគណបក្សប្រហែលប៉ុន្មាន?

នឿនៈ គណបក្សក្នុងភូមិនេះខ្ញុំដឹងតែមួយគ្រួសារទេ ព្រោះគេមិនយកចិត្តទុកដាក់ គេមិនសូវលំបាក

សុវណ្ណៈ គេចូលគណបក្សណា?

នឿនៈ ចូលមកគណបក្សប្រជាជនវិញហើយ។

សុវណ្ណៈ តែកាលពីមុនគេចូលគណបក្សណា?

នឿនៈ សម រង្ស៊ី។ អីចឹងបានខ្ញុំថា តាខ្ញុំអីពេលបោះឆ្នោតខ្ញុំថាកូនចៅអើយមិនបាច់ទៅណាទេ កន្លែងហ្នឹងហើយស្រួល មិនបាច់ទៅកន្លែងណាទេ កូនចៅខ្ញុំមិនដែលបោះឲ្យគណបក្សផ្សេងទេ មានតែគណបក្សហ៊ុនសែន បោះឲ្យតែហ្នឹង តាំងពីអើយខ្ញុំដល់ឥឡូវមិនដែលទៅណា។ លោកគ្រូខ្ញុំថាដូចគ្មានប្រយោជន៍ មើលឃើញហើយ មិនមែនថាខ្វាក់ ហើយត្រចៀកថ្លង់ឯណា ត្រចៀកនៅលឺ ភ្នែកនៅមើលឃើញ។

សុវណ្ណៈ មីងចេះខ្ញុំចង់ដឹងពីគំនិតរបស់មីងវិញ ពេលបច្ចុប្បន្នគេមានបង្រៀនរឿងរ៉ាវរបបខ្មែរក្រហមសៀវភៅនេះ នៅក្នុងកម្មវិធីសិក្សារបស់សិស្ស មីងគិតថាសិស្សទាំងអស់គួរតែរៀនឬមិនគួររៀនទេតាមសាលារៀន?

នឿនៈ សិស្សខាងយើង? សិស្សឥឡូវ?

សុវណ្ណៈ សិស្សតាមសាលារៀន តាមវិទ្យាល័យគេរៀនឥឡូវ រឿងរ៉ាវរបបខ្មែរក្រហមគួតែរៀនឬមិនគួររៀន?

នឿនៈ របបខ្មែរក្រហមនេះ?

សុវណ្ណៈ បាទ!

នឿនៈ នេះជាគំនិតរបស់ខ្ញុំយល់ដឹងទេ មិនមែនថាខ្ញុំចេះតែថាទេ គំនិតខ្ញុំយល់ដឹងដែលខ្ញុំធ្លាប់អនុវត្តន៍ ខ្ញុំធ្លាប់ធ្វើពីដើមមក ឯកសារគាប៉ុល ពត សុទ្ធតែឯកសារត្រឹមត្រូវមិនមែនថាមិនត្រឹមត្រូវ ។

សុវណ្ណៈ មីងចេះខ្ញុំចង់ពន្យល់ម្តងទៀត នៅពេលបច្ចុប្បន្នក្មេងៗនៅតាមវិទ្យាល័យ កូនសិស្សសាលារៀន គេមានរៀនរឿងរ៉ាវរបបខ្មែរក្រហមនៅសាលារៀន គេមានរៀន ។ សៀវភៅហ្នឹងគេមានឲ្យក្មេងរៀនដែរ គិតថាក្មេងគួរតែរៀន ឬមិនគួររៀនទេចំពោះសៀវភៅនេះ? នៅក្នុងកម្មវិធីសិក្សារបស់សិស្ស គិតថាក្មេងគួររៀន ឬមិនគួររៀនមីង?

នឿនៈ នេះជាយោបល់ខ្ញុំ ហើយតាមការខ្ញុំយល់ដឹងទេ បើរៀនខាងផ្នែកវិទ្យាសាស្ត្រខាងគា បើចំណុចណាដែលល្អៗ ចំណុចណាដែលមិនល្អវាមិនល្អដែរហ្នឹង មិនមែនថាទូទៅទាំងអស់ទេ តែបើខ្ញុំធ្លាប់អនុវត្តន៍កន្លងមក ខ្ញុំថាឯកសារគាត់ល្អ ទាស់តែបុគ្គលទេ បុគ្គលដែលមិនគោរពតាមបញ្ជាគាត់ច្រើនតែប្រឆាំង ។ ដូចលោកគ្រូឯងដាក់ផែនការឲ្យខ្ញុំ ឲ្យខ្ញុំកាប់ដីអីចឹង គេឲ្យកាប់ដី ខូចហ្នឹងទេ ។

សុវណ្ណៈ ខ្ញុំសុំកាត់មីងម្តងទៀត ចេះខ្ញុំចង់បញ្ជាក់តិច គិតថាក្មេងត្រូវការដឹងលឺរបបខ្មែរក្រហម ត្រូវការដឹងលឺរឿងរ៉ាវប្រវត្តិសាស្ត្រពីមុនហ្នឹងមកទេ? មីងចង់ឲ្យក្មេងរៀន ឬមិនចង់ឲ្យរៀនទេ?

នឿនៈ តាមយោបល់ខ្ញុំមិនបាច់ក៏បានដែរលោកគ្រូ ។

សុវណ្ណៈ ម៉េចអីចឹងមីង?

នឿនៈ ព្រោះវាកន្លែងណាលំបាក សិក្សាវាលំបាក ដូចថារៀន អភិវឌ្ឍន៍អីផ្សេងៗ ដូចថាយើងឲ្យធ្វើលាមក នេះបើថាយើងយកល្អវាល្អម្យ៉ាងដែរ នេះវាបង្កើនគុណភាពយើងមិនទិញជីការ៉េ យើងប្រើជីហ្នឹងមានគុណភាពដីដែរ ។

សុវណ្ណៈ មីងប្រហែលជាយល់ច្រលំបន្តិច ខ្ញុំចង់និយាយថា ប្រវត្តិសាស្ត្ររបស់ខ្មែរក្រហមវាកន្លងផុតយូរមកហើយ ត្រូវទេមីង?

នឿនៈ ចា៎!

សុវណ្ណៈ ចង់៣០-៤០ឆ្នាំមកហើយ អីចឹងរឿងរ៉ាវហ្នឹងគួរតែលើកឡើងមកនិយាយឡើងវិញ ដើម្បីឲ្យក្មេងៗជំនាន់ក្រោយមិនបានដឹងលឺ ដូចខ្ញុំអីចឹង ខ្ញុំអត់ដែលឆ្លងកាត់ អីចឹងខ្ញុំគួរតែរៀនសូត្រ មិនមែនរៀនសូត្រតាមរបបហ្នឹងទេ ចង់ថាយើងរៀនសូត្រដើម្បីឲ្យដឹងលឺថាតើក្នុងអំឡុង៧៥-៧៩មានរឿងអីកើតឡើងខ្លះ? ហើយកើតឡើងយ៉ាងម៉េចខ្លះ? ខ្ញុំគួរតែរៀនឲ្យបានដឹងលឺ ឬមិនគួររៀនឲ្យបានដឹងលឺទេ? ឬប្រវត្តិសាស្ត្រទាំងអស់ត្រូវកប់ទុកចោល

តែម្ដង មិនបាច់យកមករៀនអីទេ មិនបាច់ដឹងលឺថាមានរបបខ្មែរក្រហម មិនបាច់ទេ។ មីងគិតថាគួរតែឲ្យក្មេងៗជំនាន់ក្រោយទាំងអស់ហ្នឹងរៀន ឬមិនគួររៀនទេ? មិនមែនយើងរៀនធ្វើតាមរបបខ្មែរក្រហមទេ យើងរៀនឲ្យដឹងលឺពីរបបខ្មែរក្រហម?

នឿនៈ បើលោកគ្រូឯងមានប្រសាសន៍អីចឹងក៏ម្យ៉ាងដែរ បើថាចង់ឲ្យក្មេងៗវាជ្រួតជ្រាបនឹងរឿងរបបខ្មែរក្រហម ឲ្យរៀនខ្លះក៏ល្អ ព្រោះមានចំណុចណាខ្លាំង មានចំណុចណាខ្សោយដែរ វាល្អដើម្បីចង់ដឹងថាជំនាន់នេះយ៉ាងម៉េច ជំនាន់នោះយ៉ាងម៉េច។ បើលោកគ្រូឯងនិយាយអីចឹងក៏ខ្ញុំយល់ប៉ុណ្ណឹងដែរ។

សុវណ្ណៈ អីចឹងមីងខ្ញុំចង់សួរពីតិចទៀតចប់ហើយមីង ខ្ញុំចង់ថាសំរាប់មីងផ្ទាល់ មីងមានយោបល់អីបន្ថែមអ៊ីដែលខ្ញុំអត់បានសួរទេមីង? មានយោបល់អីខ្លះ?

នឿនៈ ខ្ញុំគ្មានយោបល់អី បើលោកគ្រូនិយាយអីចឹង ខ្ញុំមានតែចង់ឲ្យក្មេងៗដឹងពីយុទ្ធសាស្រ្ត ខាងខ្មែរក្រហមឲ្យរៀនខ្លះក៏បាន រៀនតែចំណុចណាល្អ ឲ្យដឹងថាជំនាន់នេះវាលំបាក ជំនាន់នោះវាស្រណុក ឲ្យរៀនខ្លះក៏បាន ឲ្យបានយល់ដឹងពីចំណុចល្អ ចំណុចអាក្រក់។

សុវណ្ណៈ មានយោបល់អីថែមទៀតទេមីង?

នឿនៈ អត់មានទេ។

សុវណ្ណៈ អីចឹងខ្ញុំអស់ហើយមានតែប៉ុណ្ណឹង អរគុណច្រើនដែលបានសម្ភាសន៍ខាងខ្ញុំ។

នឿនៈ ចា៎!

**ចប់**